00753929

E138

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 11 / 2011
ម៉ោង (Time/Heure): 9:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

**ចំពោះមុខ**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

**កាលបរិច្ឆេទ** ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១
**ភាសាដើម** ខ្មែរ/អង់គ្លេស/បារាំង
**ប្រភេទឯកសារ** សាធារណៈ

---

# សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ

---

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៨-៩១៤ ទូរសារ: (៨៥៥)-២៣-២១៨-៩៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh. Tel:+855(0)23 218914 Fax: +855(0)23218941 Web: www.eccc.gov.kh

E138

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ

Michiel PESTMAN

Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

ស សូវ៉ាន

Jacques VERGÈS

## ១. សេចក្ដីផ្ដើម

១. ដើម្បីធ្វើការវាយតម្លៃសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ អង្គជំនុំជម្រះសាលាដំបូង បានចាត់តាំងក្រុមអ្នកជំនាញពីរក្រុមជាបន្តបន្ទាប់ ដែលក្រុមទីមួយ មានសាស្ត្រាចារ្យ A. John Campbell វេជ្ជបណ្ឌិតជំនាញផ្នែកព្យាបាលមនុស្សចាស់ (ដោយមានការគាំទ្រពីវេជ្ជបណ្ឌិតជំនាញផ្នែកវិកលវិទ្យា ការ ស៊ុនបូណាត) និងក្រុមទីពីរ មានវេជ្ជបណ្ឌិតជំនាញផ្នែកវិកលវិទ្យាចំនួនបួនរូបគឺ វេជ្ជបណ្ឌិត ហួត លីនណា វេជ្ជបណ្ឌិត កើត ឈុនលី វេជ្ជបណ្ឌិត Seena Fazel និងវេជ្ជបណ្ឌិត Calvin Fones Soon Leng ដែលត្រូវបានស្នើឱ្យផ្ដល់សេចក្ដីសន្និដ្ឋានបន្ថែមលើសេចក្ដីសន្និដ្ឋានរបស់សាស្ត្រាចារ្យ Campbell និងដើម្បីផ្ដល់របាយការណ៍ជំនាញផ្នែកវិកលវិទ្យា។ អង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍ជំនាញចំនួនពីរផ្សេងគ្នាដែលត្រូវបានរៀបចំឡើងដោយអ្នកជំនាញទាំងនេះ[១]។ សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើង បន្ទាប់ពីមានសវនាការចំនួនពីរ ដើម្បីឱ្យមានការធ្វើបទបង្ហាញផ្ទាល់មាត់ទៅលើរបាយការណ៍របស់អ្នកជំនាញ និងសំណើរបស់ភាគីពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញទាំងនេះ[២]។

## ២. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ បានដាក់សំណើសុំចាត់តាំងអ្នកជំនាញដើម្បីកំណត់សម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ដោយធ្វើការអះអាងថា "សុខភាពខួរក្បាលរបស់ជនជាប់ចោទកំពុងតែរារាំងសមត្ថភាពរបស់មេធាវី

---

[១] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E62/3, E62/3/6 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ("របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់"), របាយការណ៍អ្នកជំនាញរៀបចំដើម្បីឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E111 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E111/8 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ ("របាយការណ៍អ្នកជំនាញវិកលវិទ្យា")។

[២] ប្រតិចារឹក ចុះថ្ងៃទី ២៩-៣០ ខែ សីហា ឆ្នាំ ២០១១ ("សវនាការលើសម្បទាក្នុងការចូលរួមសវនាការលើកទី១")។ ប្រតិចារឹក ចុះថ្ងៃទី ១៩-២០ ខែ តុលា ឆ្នាំ ២០១១ ("សវនាការលើសម្បទាក្នុងការចូលរួមសវនាការលើកទី២")។

ការពារក្ដី ក្នុងការត្រៀមរៀបចំការជំនុំជម្រះដែលនឹងមកដល់ឆាប់ៗនេះ"[៣]។ សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបទៅនឹងសំណើនេះនៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១ ហើយមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ បានធ្វើការឆ្លើយតបទៅនឹងចម្លើយតបនេះវិញ នៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១[៤]។

៣. នៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានជូនដំណឹងភាគីថា ដោយជនជាប់ចោទទាំងអស់បានស្នើឱ្យមានការវាយតម្លៃលើសម្បទាក្នុងការចូលរួមសវនាការ ទាក់ទិននឹងបញ្ហាវេជ្ជសាស្ត្រ និងវិកលចរិត អង្គជំនុំជម្រះមានបំណងងទទួលបាននូវការវាយតម្លៃលម្អិតមួយពីអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់។ អង្គជំនុំជម្រះបានផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ ដែលអង្គជំនុំជម្រះមានបំណងនឹងចាត់តាំង ហើយបានស្នើទៅក្រុមមេធាវីការពារក្ដីរបស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ឱ្យដាក់សំណួរ ឬមតិយោបល់លើបញ្ហាខួរក្បាល ឬ បញ្ហាវេជ្ជសាស្ត្រជាក់លាក់ ដែលបញ្ហាអស់ទាំងនេះមិនទាន់ត្រូវបានលើកឡើងនៅឡើយ ពាក់ព័ន្ធនឹងកូនក្ដីរបស់ខ្លួន ដើម្បីជាជំនួយដល់អ្នកជំនាញក្នុងការវាយតម្លៃ[៥]។ មេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ បានដាក់បញ្ជីសំណួរ និងបញ្ហានានា សម្រាប់អ្នកជំនាញ នៅថ្ងៃទី ២១ ខែ មីនា

---

[៣] សំណើរបស់មេធាវីការពារក្ដីស្នើសុំចាត់តាំងអ្នកជំនាញវិកលចរិតដើម្បីវាយតម្លៃសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ [...] ឯកសារលេខ E52 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សំណើរសុំចាត់តាំងអ្នកជំនាញវិកលចរិត") កថាខណ្ឌ ៣៦។ បន្ទាប់ពីបានទទួលសំណើរបស់អង្គជំនុំជម្រះ មន្ត្រីមន្ទីរឃុំឃាំង អវតក បានផ្ដល់ការអង្កេតលើកដំបូងពាក់ព័ន្ធនឹងស្ថានភាពរាងកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទទាំងបួនរូប នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ ដោយធ្វើការកត់សម្គាល់ថា អៀង ធីរិទ្ធ ដូចជាមិនអាចបង្ហាំខ្លួនបានល្អទៅនឹងលក្ខខណ្ឌនៅក្នុងមន្ទីរឃុំឃាំង (អនុស្សរណៈរបស់មន្ត្រីទំនាក់ទំនងមន្ទីរឃុំឃាំង អវតក ដែលមានចំណងជើងថា "សំណើសុំរបាយការណ៍សម្ងាត់ពាក់ព័ន្ធនឹងសុខភាពរាងកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទទាំងបួនរូប" (សំណុំរឿង ០០២) ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E31/1។ *សូមមើលផងដែរ* សំណើសុំរបាយការណ៍សម្ងាត់ពាក់ព័ន្ធនឹងសុខភាពរាងកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទទាំងបួនរូប" (សំណុំរឿង ០០២) ឯកសារលេខ E31 ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១១)។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំចាត់តាំងអ្នកជំនាញវិកលចរិតរបស់ អៀង ធីរិទ្ធ ឯកសារលេខ E52/1 ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១។ មេធាវីការពារក្ដីបានធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើសុំចាត់តាំងអ្នកជំនាញវិកលចរិត ដើម្បីវាយតម្លៃសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ" ឯកសារលេខ E52/2 ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១។

[៥] អនុស្សរណៈផ្ញើជូនមេធាវីការពារក្ដី អៀង ធីរិទ្ធ និង នួន ជា ឯកសារលេខ E62 ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១។

ឆ្នាំ ២០១១[៦]។

៤. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានចាត់តាំងសាស្ត្រាចារ្យ A. John Campbell ("អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់") ឱ្យធ្វើការវាយតម្លៃវេជ្ជសាស្ត្រលើជនជាប់ចោទទាំងអស់ដែលមានបំណងចង់ឱ្យអ្នកជំនាញវាយតម្លៃ ដោយបានស្នើសុំសាស្ត្រាចារ្យឱ្យរៀបចំរបាយការណ៍ដាច់ដោយឡែកពីគ្នាពាក់ព័ន្ធនឹងជនជាប់ចោទនីមួយៗ[៧]។

៥. បន្ទាប់ពីធ្វើការវាយតម្លៃរួច សាស្ត្រាចារ្យ Campbell បានធ្វើការចង្អុលបង្ហាញក្នុងលិខិតរបស់លោកផ្ញើជូនអង្គជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១ ថា ក្នុងអំឡុងពេលធ្វើការពិនិត្យល្អិតល្អន់លើជនជាប់ចោទ អៀង ធីរិទ្ធ នោះ លោកបានកត់សម្គាល់ឃើញការធ្លាក់ចុះសតិបញ្ញាច្រើនជាងពេលធ្វើការអង្កេតមើលលើកមុនរបស់សាស្ត្រាចារ្យ ការ ស៊ុនបូណាត និងសាស្ត្រាចារ្យរង Philip Brinded នៅពេលដែលពួកគាត់ទាំងពីរបានធ្វើការពិនិត្យជនជាប់ចោទនៅខែ តុលា ឆ្នាំ ២០០៩[៨]។ អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់បានជម្រាបជូនអង្គជំនុំជម្រះថា លោកត្រូវការឱ្យ

---

[៦] សំណួររបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សម្រាប់លោកសាស្ត្រាចារ្យ Campbell អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ ឯកសារលេខ E62/2 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១។

[៧] ដីកាចាត់តាំងអ្នកជំនាញ ឯកសារលេខ E62/3 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ ("ដីកាចាត់តាំងអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់") កថាខណ្ឌ ៤, ៦។ មុននឹងធ្វើការវាយតម្លៃ អង្គជំនុំជម្រះបានប្រគល់ឱ្យអ្នកជំនាញ នូវបញ្ជីព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿង ឬដែលរក្សាទុកនៅមន្ទីរពេទ្យកាល់ម៉ែត ឬនៅការិយាល័យរដ្ឋបាល អវតក (*សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងផ្ញើជូនអ្នកជំនាញ ដែលមានចំណងជើងថា "ប្រភេទនៃឯកសារវេជ្ជសាស្ត្រដែលត្រូវបានផ្តល់ជូនជាមុនសម្រាប់ការវាយតម្លៃរបស់លោកលើជនជាប់ចោទ នួន ជា, អៀង ធីរិទ្ធ និង អៀង សារី" ឯកសារលេខ E62/3/1 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១)។ ជនជាប់ចោទ ខៀវ សំផន បានធ្វើការបង្ហាញថា គាត់មិនចូលរួមក្នុងការវាយតម្លៃនេះទេ (ដីកាចាត់តាំងអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៤)។

[៨] លិខិតរបស់សាស្ត្រាចារ្យ Campbell ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E62/3/3.1 ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១។ នៅក្នុងរបាយការណ៍ខែ វិច្ឆិកា ឆ្នាំ ២០០៩ សាស្ត្រាចារ្យ ការ ស៊ុនបូណាត និង Brinded បានកត់សម្គាល់ថា អៀង ធីរិទ្ធ មានការវង្វេងស្មារតីកម្រិតស្រាលដោយសារអាយុ ហើយគាត់នឹងភ័ន្តច្រឡំនៅពេលសួរសំណួរវែង ឬនៅពេលដែលគាត់យល់ឃើញថា ខ្លឹមសារនៃបទសម្ភាសន៍ពាក់ព័ន្ធនឹងអារម្មណ៍នោះអាចជាបញ្ហា (របាយការណ៍កោសល្យវិច័យផ្នែកចិត្តសាស្ត្រពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ ឯកសារលេខ B37/9/8 ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៩ ("របាយការណ៍អ្នកជំនាញរបស់ កសចស") ទំព័រ ៨)។ នាពេលនោះ អ្នកជំនាញយល់ឃើញថា ជនជាប់ចោទអាចធ្វើឱ្យប្រសើរឡើងវិញតាមរយៈការប្រើប្រាស់

មានការបញ្ជាក់បន្ថែមថា ការរកឃើញរបស់លោកមិនមែនបណ្ដាលមកពីការធ្វើតេស្តលើបុគ្គលដែលមានសាវតារប្បធម៌ផ្សេងពីលោកនោះទេ ហើយលោកបានផ្ដល់អនុសាសន៍ឱ្យសាស្ត្រាចារ្យ ការ ស៊ុនបូណាត ធ្វើការវាយតម្លៃលើជនជាប់ចោទបន្ថែមទៀត[៩]។ នៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១ សាស្ត្រាចារ្យ ការ ស៊ុនបូណាត បានដាក់ជូនរបាយការណ៍របស់លោក ដែលក្នុងនោះលោកបានធ្វើការសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានការចុះខ្សោយខាងមុខងារសតិបញ្ញា[១០]។ បន្ទាប់ពីអង្គជំនុំជម្រះបានស្នើឱ្យធ្វើការបំភ្លឺបញ្ជាក់លើបញ្ហាមិនស៊ីចង្វាក់គ្នាមួយចំនួននៅក្នុងរបាយការណ៍របស់សាស្ត្រាចារ្យ ការ ស៊ុនបូណាត អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានផ្ដល់នូវការបំភ្លឺជាច្រើនពាក់ព័ន្ធទៅនឹងរបាយការណ៍នេះ នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១១[១១]។

៦. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ សាស្ត្រាចារ្យ Campbell បានដាក់ជូនរបាយការណ៍របស់លោកពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ (របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាល

---

ឯកសារដែលបានសរសេរទុក ហើយសមត្ថភាពខួរក្បាលរបស់គាត់អាចឱ្យគាត់ចូលរួមក្នុងដំណើរការនីតិវិធីបានដោយមានជំនួយពីមេធាវីការពារក្ដីរបស់គាត់ (របាយការណ៍អ្នកជំនាញរបស់ កសចស ទំព័រ ៨)។

[៩] លិខិតរបស់លោកសាស្ត្រាចារ្យ Campbell ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E62/3/3.1 ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ដីកាបង្គាប់ឱ្យធ្វើការវាយតម្លៃបន្ថែមលើ អៀង ធីរិទ្ធ ឯកសារលេខ E62/3/3 ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ (ដោយបានធ្វើការកត់សម្គាល់លើអនុសាសន៍របស់លោកសាស្ត្រាចារ្យ Campbell ឱ្យមានការវាយតម្លៃបន្ថែមទៀតដោយវេជ្ជបណ្ឌិត ការ ស៊ុនបូណាត ហើយអនុញ្ញាតឱ្យលោកធ្វើការទាក់ទងជាមួយលោកសាស្ត្រាចារ្យ Campbell ព្រមទាំងអាចចេញចូលមន្ទីរឃុំឃាំង អវតក សម្រាប់គោលបំណងនេះផងដែរ)។

[១០] របាយការណ៍កោសល្យវិច័យចិត្តសាស្ត្រពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ ឯកសារលេខ E62/3/6.1 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៥ (រួមបញ្ចូលទាំងកម្រិតនៃការចុះខ្សោយផ្នែកមុខងារប្រព័ន្ធប្រសាទនេះ គឺ "ទំនងជាស្ថិតក្នុងចន្លោះពីចំណុចខ្ពស់បំផុតនៃការចុះខ្សោយកម្រិតស្រាល និងចំណុចទាបបំផុតនៃការចុះខ្សោយកម្រិតមធ្យម"។

[១១] សំណើរបស់អង្គជំនុំជម្រះឱ្យធ្វើការបំភ្លឺលើរបាយការណ៍របស់អ្នកជំនាញរៀបចំដោយសាស្ត្រាចារ្យ ការ ស៊ុនបូណាត ឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញ ឯកសារលេខ E62/3/3 E62/3/6.2 ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១១។ បន្ទាប់ពីបានទទួលសេចក្ដីបញ្ជាក់ពីសាស្ត្រាចារ្យ ការ ស៊ុនបូណាត សាស្ត្រាចារ្យ Campbell បានធ្វើការបង្ហាញថា សេចក្ដីបញ្ជាក់ទាំងនេះមិនមានឥទ្ធិពលលើសេចក្ដីសន្និដ្ឋានរបស់លោកឡើយ ឬតម្រូវឱ្យមានការដាក់បន្ថែមទៅលើរបាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ឡើយ។ (ទំនាក់ទំនងតាមអ៊ីមែលរវាងសាស្ត្រាចារ្យ Campbell និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឯកសារលេខ E62/3/6.3 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១)។

មនុស្សចាស់)។ របាយការណ៍នោះបានសន្និដ្ឋានថា អៀង ធីរិទ្ធមានជំងឺវង្វេងស្មារតីធ្ងន់ធ្ងរ អាចថាជាជំងឺ Alzheimer[១២]។ ដោយហេតុថា អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់បានពិចារណាថា ការប្រើឱសថព្យាបាលជំងឺរបស់ជនជាប់ចោទអាចធ្វើឲ្យកាន់តែចុះខ្សោយមុខងារសតិបញ្ញាបន្ថែមទៀតនោះ លោកបានផ្តល់អនុសាសន៍ឲ្យមានការកាត់បន្ថយការប្រើឱសថទាំងនោះបន្តិចម្តងៗ ហើយធ្វើការវាយតម្លៃជាថ្មី បន្ទាប់ពីការឈប់ប្រើឱសថទាំងនោះ[១៣]។ នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ លោកវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទនៅមន្ទីរពេទ្យកាល់ម៉ែតបានឯកភាពធ្វើការកាត់បន្ថយឱសថសម្រាប់ព្យាបាលជំងឺផ្លូវចិត្ត ហើយសាស្ត្រាចារ្យ Campbell បានធ្វើការពិនិត្យជនជាប់ចោទជាថ្មី នៅចន្លោះថ្ងៃទី ២៤ និង ២៦ ខែ សីហា ឆ្នាំ ២០១១[១៤]។

៧. នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ នៅក្នុងសវនាការបឋម អង្គជំនុំជម្រះបានស្នើឲ្យមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ដាក់ជូនមកអង្គជំនុំជម្រះនូវការអង្កេតរបស់ខ្លួនលើរបាយការណ៍

---

[១២] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៤០។

[១៣] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៤២-៤៥ (ដែលណែនាំឲ្យមាន "ការកាត់បន្ថយការប្រើឱសថព្យាបាលជំងឺផ្លូវចិត្តបន្តិចម្តងៗជាដំណាក់កាល ដោយត្រូវស្ថិតក្រោមការតាមដានយ៉ាងជិតដល់ពីសំណាក់វេជ្ជបណ្ឌិតមន្ទីរពេទ្យកាល់ម៉ែតដែលផ្តល់សេវាថែទាំសុខភាពជូនលោកស្រី" ហើយជាពិសេស ការកាត់បន្ថយឱសថ clonazepam ជាដំណាក់កាលក្នុងអំឡុងពេលបួនសប្តាហ៍ បន្ទាប់មកទៀត មានការកាត់បន្ថយប្រហែលគ្នានេះដែរសម្រាប់ឱសថ quetiapine ប្រសិនបើការកាត់បន្ថយឱសថ clonazepam មិនមានប្រតិកម្មប្រឆាំងទេ)។

[១៤] នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១១ ការិយាល័យរដ្ឋបាល អវតក បានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា មន្ទីរពេទ្យកាល់ម៉ែតបានចាប់ផ្តើមកាត់បន្ថយឱសថព្យាបាលជំងឺផ្លូវចិត្តទាំងនេះនៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ (ទំនាក់ទំនងជាមួយមន្ទីរពេទ្យកាល់ម៉ែត យោងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំព័ត៌មានស្តីពីការព្យាបាល អៀង ធីរិទ្ធ ឯកសារលេខ E62/3/6/5 ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១១)។ *សូមមើលផងដែរ* ទំនាក់ទំនងរវាងសាស្ត្រាចារ្យ Campbell និងមន្ទីរពេទ្យកាល់ម៉ែត ពាក់ព័ន្ធទៅនឹងរបាយការណ៍អ្នកជំនាញវេជ្ជសាស្ត្រលើ អៀង ធីរិទ្ធ ឯកសារលេខ E62/3/6/4 ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១១។ ប្រតិចារឹកនៃកិច្ចប្រជុំតាមប្រព័ន្ធទូរសោតទស្សន៍រវាងវេជ្ជបណ្ឌិតមន្ទីរពេទ្យកាល់ម៉ែត និងសាស្ត្រាចារ្យ Campbell ឯកសារលេខ E62/3/6/4.4 ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១។ របាយការណ៍ស្តីពីកិច្ចពិភាក្សាតាមប្រព័ន្ធទូរសោតទស្សន៍ជាមួយវេជ្ជបណ្ឌិតមន្ទីរពេទ្យកាល់ម៉ែត ដែលមើលថែទាំ អៀង ធីរិទ្ធ ឯកសារលេខ E62/3/6/4.1 ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ និងរបាយការណ៍ស្តីពីការពិភាក្សាតាមប្រព័ន្ធទូរសោតទស្សន៍ប្រព្រឹត្តទៅនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ រវាងបុគ្គលិកវេជ្ជសាស្ត្រមន្ទីរពេទ្យកាល់ម៉ែត ជាមួយសាស្ត្រាចារ្យ Campbell ស្តីពីរបបនៃការប្រើឱសថសម្រាប់ជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E62/3/6/4.2 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១។

របស់អ្នកជំនាញ ត្រឹមថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ហើយភាគីដទៃទៀត ឲ្យបានត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១[១៥]។ នៅក្នុងសេចក្តីអង្កេតរបស់ខ្លួន មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បានយល់ស្របនឹងសេចក្តីសន្និដ្ឋានរបស់សាស្ត្រាចារ្យ Campbell ដែលថា អៀង ធីរិទ្ធ មិនមានសមត្ថភាពចូលរួមពេញលេញនៅក្នុងការជំនុំជម្រះ និងការអនុវត្តនូវសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌របស់គាត់នោះទេ[១៦]។ សហព្រះរាជអាជ្ញាបានលើកឡើងថា សាស្ត្រាចារ្យ Campbell ក្នុងនាមជាសាស្ត្រាចារ្យជំនាញផ្នែកព្យាបាលមនុស្សចាស់ មិនមានគុណវុឌ្ឍិធ្វើរោគវិនិច្ឆ័យលើជំងឺជាក់លាក់របស់ជនជាប់ចោទឡើយ ហើយបានស្នើឲ្យមានការចាត់តាំងអ្នកជំនាញចំនួនពីររូបបន្ថែមទៀត ដែលជាអ្នកជំនាញមានបទពិសោធន៍ និងជំនាញផ្នែកជំងឺវង្វេងស្មារតី[១៧]។

៨. បន្ទាប់ពីធ្វើការវាយតម្លៃជនជាប់ចោទជាថ្មី សាស្ត្រាចារ្យ Campbell បានដាក់ជូនរបាយការណ៍បន្ថែម នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ដោយធ្វើការបញ្ជាក់ថា សេចក្តីសន្និដ្ឋានរបស់លោកលើសមត្ថភាពរបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមការពារខ្លួនរបស់លោកស្រី មិនមានការផ្លាស់ប្តូរទេ[១៨]។ អង្គជំនុំជម្រះបានបើកសវនាការមុនអង្គសេចក្តីលើសម្បទារបស់ជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១[១៩]។

៩. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការចាត់តាំងអ្នកជំនាញផ្នែកវិកលវិទ្យាចំនួនបួនរូប ដើម្បីធ្វើសេចក្តីសន្និដ្ឋានបន្ថែមលើសេចក្តីសន្និដ្ឋានរបស់សាស្ត្រាចារ្យ

---

[១៥] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៣២-៣៣។

[១៦] មតិយោបល់របស់មេធាវីការពារក្តី អៀង ធីរិទ្ធ លើរបាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់របស់សាស្ត្រាចារ្យ Campbell ឯកសារលេខ E62/3/6/1 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៣ ១២ ១៤ និង ១៨។

[១៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាលើរបាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E62/3/6/2 ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ២១។

[១៨] របាយការណ៍វាយតម្លៃបន្ថែមពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ អនុលោមតាមដីកាចាត់តាំងអ្នកជំនាញ E62/3 របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E62/3/12 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ("របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់") ទំព័រ ៨។

[១៩] ដីកាកំណត់កាលបរិច្ឆេទសវនាការស្តីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ឯកសារលេខ E110 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១។

Campbell ពាក់ព័ន្ធនឹងការចុះខ្សោយផ្នែកសតិបញ្ញារបស់ អៀង ធីរិទ្ធ[២០]។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យមេធាវីការពារក្តី អៀង ធីរិទ្ធ និងសហព្រះរាជអាជ្ញា ដាក់សំណួរ ឬមតិយោបល់លើបញ្ហាសតិបញ្ញា ឬវេជ្ជសាស្ត្រ ពាក់ព័ន្ធនឹងជនជាប់ចោទ ដែលមិនទាន់ត្រូវបានលើកឡើងនៅឡើយ ដើម្បីជាជំនួយដល់អ្នកជំនាញផ្នែកវិកលវិទ្យាសម្រាប់ធ្វើការវាយតម្លៃ[២១]។ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ មេធាវីការពាររបស់ អៀង ធីរិទ្ធ និងសហព្រះរាជអាជ្ញា បានដាក់សំណួរ និងមតិយោបល់សម្រាប់ជាការពិចារណារបស់អ្នកជំនាញ[២២]។

១០. បន្ទាប់ពីធ្វើការវាយតម្លៃជនជាប់ចោទ អ្នកជំនាញផ្នែកវិកលវិទ្យា បានដាក់ជូនរបាយការណ៍រួមមួយ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ ស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ អ្នកជំនាញផ្នែកវិកលវិទ្យាបានធ្វើការសន្និដ្ឋានថា នាពេលបច្ចុប្បន្ន អៀង ធីរិទ្ធ មិនមានការយល់ដឹងគ្រប់គ្រាន់អំពីដំណើរការនីតិវិធីតុលាការទេ ហើយសមត្ថភាពរបស់លោកស្រីនឹងមានការប្រែប្រួល ដោយសារជំងឺវង្វេងស្មារតី ហើយវិធានការណ៍សម្រាប់ទប់ទល់នឹងសមត្ថភាពដែលចុះខ្សោយរបស់លោកស្រី (ដូចជាការធ្វើសេចក្តីសង្ខេបផ្ទាល់មាត់នៃដំណើរការនីតិវិធី ការពិភាក្សាជាបន្តបន្ទាប់ និងទៀងទាត់ជាមួយមេធាវីជាតិនៅក្នុងអឡុងពេលជំនុំជម្រះ) ដូចជាមិនទំនងជាធ្វើឲ្យមានការប្រសើរឡើងផ្នែកសមត្ថភាពសតិបញ្ញារបស់លោកស្រី ដល់កម្រិតមួយដែលគាត់អាចមានការយល់ដឹងគ្រប់គ្រាន់ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីច្បាប់នោះទេ[២៣]។

១១. នៅក្នុងអំឡុងពេលសវនាការ ថ្ងៃទី ១៩ និងទី ២០ ខែ តុលា ឆ្នាំ ២០១១ លោកវេជ្ជបណ្ឌិត ហួត

---

[២០] ដីកាចាត់តាំងអ្នកជំនាញ ឯកសារលេខ E111 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ("ដីកាចាត់តាំងអ្នកជំនាញវិកលវិទ្យា") (ចាត់តាំងវេជ្ជបណ្ឌិត ហួត លីនណា ប្រទេសកម្ពុជា វេជ្ជបណ្ឌិត កើត ឈុនលី ប្រទេសកម្ពុជា វេជ្ជបណ្ឌិត Seena Fazel ចក្រភពអង់គ្លេស និង វេជ្ជបណ្ឌិត Calvin Fones Soon Leng ប្រទេសសិង្ហបុរី (ដែលរួមគ្នាហៅថា "អ្នកជំនាញផ្នែកវិកលវិទ្យា"))។

[២១] ដីកាចាត់តាំងអ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ១១។

[២២] សំណួរនិងមតិយោបល់របស់សហព្រះរាជអាជ្ញាសម្រាប់អ្នកជំនាញវិកលវិទ្យាពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E111/2 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១។ សំណួរ និងមតិយោបល់របស់មេធាវីការពារក្តី អៀង ធីរិទ្ធ សម្រាប់អ្នកជំនាញអនុលោមតាមដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E111/3 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១។

[២៣] របាយការណ៍អ្នកជំនាញឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E111 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១, ឯកសារលេខ E111/8 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ ("របាយការណ៍អ្នកជំនាញវិកលវិទ្យា") កថាខណ្ឌ ៥១។

លីនណា និងវេជ្ជបណ្ឌិត Seena Fazel (ដែលត្រូវបានជ្រើសរើសជាតំណាងអ្នកជំនាញផ្នែកវិកលវិទ្យា ដើម្បីផ្តល់សក្ខីកម្មក្នុងនាមអ្នកជំនាញទាំងបួនរូប) ត្រូវបានចោទសួរ ហើយមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើររបស់ខ្លួនពាក់ព័ន្ធនឹងសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ អង្គជំនុំជម្រះបានស្នើភាគីពាក់ព័ន្ធឲ្យធ្វើការឆ្លើយតបទៅនឹងសំណួរខាងក្រោមនេះ នៅក្នុងអំឡុងពេលសវនាការ៖

I. តើជនជាប់ចោទមួយរូបអាចត្រូវបានចាត់ទុកថា ពុំមានសម្បទាផ្នែកបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរ ឬទេ ដោយគ្រាន់តែរកឃើញថា លក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យនានា ដូចដែលបានបង្ហាញនៅក្នុងសំណុំរឿង *Strugar* ត្រូវបានបំពេញនោះ ឬមួយក៏ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យទាំងអស់រួមបញ្ចូលគ្នា នៅពេលធ្វើការវាយតម្លៃសម្បទាជនជាប់ចោទ?

II. តើការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកប្រព័ន្ធប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលសាស្ត្រាចារ្យ Campbell និងអ្នកជំនាញវិកលវិទ្យាបានរកឃើញ ពិតជាធ្វើឲ្យជនជាប់ចោទរូបនេះ គ្មានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ស្របតាមបទដ្ឋានតម្រូវចាំបាច់នៅក្នុងសំណុំរឿង *Strugar* មែន ឬទេ?

III. តើកម្រិតនៃការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកសមត្ថភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការ ក) ឆ្លើយតបទៅនឹងបទចោទ ខ) ណែនាំដល់មេធាវី គ) ផ្តល់សក្ខីកម្ម និង ឃ) យល់អំពីលក្ខណៈនៃបទចោទ, ការប្រព្រឹត្តទៅនៃដំណើរការនីតិវិធី, យល់លម្អិតអំពីភស្តុតាង និងផលវិបាក នៃកិច្ចដំណើរការនីតិវិធី បញ្ជាក់ថា ជនជាប់ចោទរូបនេះពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរ ឬទេ ដោយពិចារណាទៅលើកត្តាដែលថា ជនជាប់ចោទមានមេធាវីតំណាង និងអាចអនុវត្តសិទ្ធិទាំងអស់នេះបានមួយផ្នែកតាមរយៈមេធាវីរបស់ខ្លួននោះ?

IV. ដូចដែលអ្នកជំនាញទាំងអស់បានរកឃើញថា ស្ថានភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺកាន់តែទ្រុឌទ្រោមទៅៗ និងអាចពន្យារពេលកិច្ចដំណើរការនីតិវិធីមិនឈប់ឈរ ដូចជាត្រូវពិនិត្យបន្ថែម ឬជាប្រចាំ ឬស្ថានភាពប្រចាំថ្ងៃរបស់គាត់មិននឹងនរជាដើម។ ដោយសារកត្តាទាំងអស់នេះអាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទផ្សេងទៀត ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងអាចអូសបន្លាយកិច្ចដំណើរការនីតិវិធីលើសំណុំរឿងលេខ ០០២

ទាំងមូល តើភាគីយល់ឃើញថា ជាផលប្រយោជន៍នៃយុត្តិធម៌ដែរ ឬទេ ដែលត្រូវបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីកិច្ចដំណើរការនីតិវិធីទាំងនេះ ដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* (ដូចជាជម្រើស ដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលជនជាប់ចោទត្រូវបានរកឃើញថា ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ)?

V. តើបច្ច័យអ្វីខ្លះចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ដែលអាចកើតចេញពីដីកាបំបែកកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាននេះ?[២៤]

## ៣. <u>សារណា</u>

១២. មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ស្នើឡើងថា ជនជាប់ចោទមិនមានសម្បទាចូលរួមសវនាការទេ ហើយនីតិវិធីប្រឆាំងនឹងជនជាប់ចោទគួរត្រូវបានបញ្ចប់[២៥]។ របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ និងរបាយការណ៍របស់អ្នកជំនាញវិកលវិទ្យាមានអត្ថន័យខ្លឹមសារដូចគ្នានៅក្នុងការសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងស្មារតីធ្ងន់ធ្ងរ[២៦]។ ដោយសារជនជាប់-ចោទមិនមានសមត្ថភាពក្នុងការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការតម្រូវឱ្យជនជាប់ចោទចូលរួមសវនាការគឺជាការមិនត្រឹមត្រូវទេ[២៧]។

១៣. នៅពេលលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌនានាត្រូវបានបំពេញដូចនៅក្នុងសំណុំរឿង *Strugar* នោះ មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ស្នើឡើងថា ជនជាប់ចោទត្រូវបានកំណត់ថា មិនមានសម្បទាក្នុងការចូលរួមសវនាការ[២៨]។ អៀង ធីរិទ្ធ ខ្វះការចងចាំទាំងរយៈពេលខ្លី និងរយៈពេលយូរ ដែលវាធ្វើឱ្យប៉ះពាល់គ្រប់លក្ខខណ្ឌសមត្ថភាពនីមួយៗ ដែលត្រូវបានកត់សម្គាល់នៅក្នុងសំណុំរឿង *Strugar*[២៩]។ ការប្រើមេធាវីនឹងមិនអនុញ្ញាតឱ្យជនជាប់ចោទ អៀង ធីរិទ្ធ ចូលរួម

---

[២៤] ដីកាកំណត់កាលបរិច្ឆេទសវនាការថ្ងៃទី ១៩ និងទី ២០ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E129 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៤-៥។

[២៥] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៩០។

[២៦] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៩០-៩២។

[២៧] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៩៣-៩៤។

[២៨] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៩៣។

[២៩] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៩៧។

ដោយមានអត្ថន័យ នៅក្នុងដំណើរការនីតិវិធីប្រឆាំងនឹងគាត់ឡើយ ដោយសារតែការចុះខ្សោយនៃការ ចងចាំរបស់គាត់រារាំងសមត្ថភាពរបស់គាត់ក្នុងការណែនាំមេធាវី ពាក់ព័ន្ធនឹងការប្រព្រឹត្តិដែលគាត់ ត្រូវបានចោទប្រកាន់[៣០]។

១៤. ផ្ទុយទៅវិញ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងរកឃើញថា បច្ចុប្បន្ននេះ លោកស្រី អៀង ធីរិទ្ធ គ្មានសម្បទាក្នុងការចូលរួមការជំនុំជម្រះទេ ប៉ុន្តែស្ថានភាពរបស់គាត់អាចប្រសើរឡើងក្នុងរយៈពេលណាមួយនោះ មេធាវីការពារក្តីរបស់គាត់បានស្នើថា តុលាការគប្បីបង្គាប់ឱ្យមានការពិនិត្យស្ថានភាពរបស់គាត់ឡើងវិញ បន្ទាប់ពីការអនុវត្តការប្រើឱសថតាមវេជ្ជបញ្ជា ការព្យាបាល ឬបន្ទាប់ពីបានអនុវត្តវិធានការឃុំគ្រងរួចរាល់ហើយ[៣១]។ នៅក្នុងរយៈពេលរង់ចាំការសម្រេចនេះ "អង្គជំនុំជម្រះអាចសម្រេចបន្តការឃុំខ្លួនលោកស្រី អៀង ធីរិទ្ធ ក្នុងរយៈពេលធ្វើការវាយតម្លៃនេះ ឬអាចសម្រេចឱ្យគាត់នៅក្រៅឃុំជាបណ្តោះអាសន្ន"[៣២]។ នៅទីបំផុត មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ បានបញ្ជាក់ថា សហព្រះរាជអាជ្ញាជាអ្នកមានបន្ទុកក្នុងការបង្ហាញភស្តុតាងថា ជនជាប់ចោទមានសម្បទា ក្នុងការចូលរួមការជំនុំជម្រះ[៣៣]។

១៥. សហព្រះរាជអាជ្ញាបានបញ្ជាក់ថា នៅដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចកំណត់ឱ្យបានច្បាស់ថា លោកស្រី អៀង ធីរិទ្ធ គ្មានសម្បទាក្នុងការចូលរួមការជំនុំជម្រះបានទេ[៣៤]។ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា លោកស្រី អៀង ធីរិទ្ធ មានជំងឺចុះខ្សោយការចងចាំគួរឱ្យគត់សម្គាល់ ប៉ុន្តែបានកត់សម្គាល់ថា ការរកឃើញរបស់អ្នកជំនាញខាងវិកលវិទ្យាថា អ្នកស្រី អៀង ធីរិទ្ធ នៅមានសមត្ថភាពប្រាំក្នុងចំណោមសម្បទាទាំងប្រាំពីរដែលបានបញ្ជាក់ក្នុងរឿងក្តី *Strugar*[៣៥]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិនិត្យឱ្យបានគ្រប់

---

[៣០] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៩៧, ១០១។

[៣១] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៤។

[៣២] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៤ (ទោះបីជាយ៉ាងណាក្តី មានការទទួលស្គាល់ថា ស្ថានភាពរបស់គាត់អាចប្រសើរជាងមុន ប្រសិនបើគាត់បានស្ថិតនៅក្នុងបរិយាកាសជំរុញផ្លូវចិត្ត ជំនួសការបន្តការឃុំខ្លួនគាត់)។

[៣៣] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៨៦ ដល់ ៨៩។

[៣៤] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៦។

[៣៥] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៧។

ជម្រើសដែលមាន មុននឹងសម្រេចថា អ្នកស្រី អៀង ធីរិទ្ធ គ្មានសម្បទាក្នុងការចូលរួមការជំនុំជម្រះ[៣៦]។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា បរិយាកាសដែលមានកម្រិតនៅក្នុងមន្ទីរឃុំឃាំង និងការបន្តប្រើថ្នាំប្រឆាំងជំងឺផ្លូវចិត្តមួយប្រភេទអាចជាកត្តារួមផ្សំ ដែលធ្វើឱ្យសតិបញ្ញារបស់គាត់ចុះខ្សោយ[៣៧]។ ស្ថានភាពសតិបញ្ញារបស់គាត់អាចប្រសើរឡើង កាលណា បញ្ឈប់ការប្រើឱសថប្រឆាំងនឹងជំងឺផ្លូវចិត្តទាំងស្រុង និងនៅពេលប្រើឱសថមួយប្រភេទ តាមយោបល់របស់សាស្ត្រាចារ្យ CAMPBELL[៣៨]។ សហព្រះរាជអាជ្ញាបានបញ្ជាក់បន្ថែមថា សម្បទារបស់គាត់អាចប្រសើរឡើង កាលណាតុលាការប្រើរូបថត វីដេអូ និងឯកសារដែលទាក់ទិននឹងដំណើរការនីតិវិធីដើម្បីជួយរំឭកការចងចាំរបស់គាត់[៣៩]។

១៦ ទោះបីជាមានការទទួលស្គាល់ថា ការបាត់បង់ទាំងស្រុងនូវសម្បទាណាមួយក្នុងចំណោមសម្បទាដែលបានកំណត់ក្នុងរឿងក្តី *Strugar* នឹងនាំឱ្យជនជាប់ចោទគ្មានសមត្ថភាព អនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយមានប្រសិទ្ធភាពក្តី ក៏សហព្រះរាជអាជ្ញានៅតែអះអាងថា អ្នកស្រី អៀង ធីរិទ្ធ មិនមែនបាត់បង់សមត្ថភាពទាំងនោះទាំងស្រុងទេ[៤០]។ សហព្រះរាជអាជ្ញាបានអះអាងថា ទោះបីជាតុលាការរកឃើញថា អ្នកស្រី អៀង ធីរិទ្ធ គ្មានសម្បទាក៏ដោយ ក៏មិនមានមូលដ្ឋានណាមួយ ដែលគាំទ្រការបញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងគាត់ដែរ ពីព្រោះមាត្រា ៧ និង ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២00៧ មិនបានចែងតម្រូវឱ្យតុលាការបញ្ឈប់ដំណើរការនីតិវិធីដោយសំអាងលើមូលហេតុថា ជនជាប់ចោទគ្មានសម្បទាចូលរួមក្នុងការជំនុំជម្រះឡើយ[៤១]។

១៧ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា អ្នកស្រី អៀង ធីរិទ្ធ ពិតជាមានសម្បទាចូលរួមក្នុងការជំនុំជម្រះ ហើយការគាំទ្រពីមេធាវីរបស់គាត់ នឹងផ្តល់លទ្ធភាពឱ្យគាត់ចូលរួមក្នុងកិច្ចដំណើរការ

---

[៣៦] ប្រតិចារឹក ថ្ងៃទី ២0 ខែ តុលា ឆ្នាំ ២0១១ ទំព័រ ១0៩។
[៣៧] ប្រតិចារឹក ថ្ងៃទី ២0 ខែ តុលា ឆ្នាំ ២0១១ ទំព័រ ១0៨។
[៣៨] ប្រតិចារឹក ថ្ងៃទី ២0 ខែ តុលា ឆ្នាំ ២0១១ ទំព័រ ១១៨។
[៣៩] ប្រតិចារឹក ថ្ងៃទី ២0 ខែ តុលា ឆ្នាំ ២0១១ ទំព័រ ១0៩ ដល់ ១១0។
[៤0] ប្រតិចារឹក ថ្ងៃទី ២0 ខែ តុលា ឆ្នាំ ២0១១ ទំព័រ ១១0។
[៤១] ប្រតិចារឹក ថ្ងៃទី ២0 ខែ តុលា ឆ្នាំ ២0១១ ទំព័រ ១១៦។

នីតិវិធីបាន[៤២]។ តុលាការមិនគប្បីសម្រេចឲ្យគាត់នៅក្រៅឃុំទេ ពីព្រោះគាត់ទទួលបានការថែទាំល្អប្រសើរនៅក្នុងមន្ទីរឃុំឃាំង[៤៣]។ម្យ៉ាងវិញទៀត នឹងមានសំណួរជាច្រើនក្នុងការសួរដេញដោលសំណុំរឿង ០០២ ដែលនឹងតម្រូវឲ្យគាត់ឆ្លើយតប[៤៤]។

១៨ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ដូចដែលបានរៀបរាប់ក្នុងរបាយការណ៍អ្នកជំនាញ អាកប្បកិរិយារបស់អ្នកស្រី អៀង ធីរិទ្ធ បង្ហាញឲ្យឃើញថា គាត់មានសម្បទាចូលរួមក្នុងការជំនុំជម្រះ[៤៥]។ការដែលគាត់បដិសេធចំពោះពិរុទ្ធភាពរបស់គាត់ ការមិនព្រមពិភាក្សាពីការចោទប្រកាន់ប្រឆាំងនឹងគាត់ ឬពីផលវិបាកនៃកាត់ទោស គឺស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងប្រតិកម្មរបស់បុគ្គលដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[៤៦]។

១៩ ពាក់ព័ន្ធនឹងសំណួរទី ៤ (ក្នុងកថាខណ្ឌ ១១ ខាងលើ) មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធបានអះអាងថា តុលាការត្រូវតែបំបែក និងបញ្ឈប់ដំណើរការនីតិវិធីប្រឆាំងអ្នកស្រី អៀង ធីរិទ្ធដោយសារស្ថានចុះខ្សោយជាលំដាប់របស់ជនជាប់ចោទ នឹងនាំឲ្យមានការពន្យារពេលជាបន្តបន្ទាប់ដល់ដំណើរការនីតិវិធី[៤៧]។ មេធាវីការពារក្តីបានអះអាងបន្ថែមថា បច្ចុប្បន្ននេះអ្នកស្រី អៀង ធីរិទ្ធគ្មានសម្បទាក្នុងការណែនាំដល់មេធាវីទេ ហើយខ្លួននឹងត្រូវការពេលវេលាបន្ថែម ដើម្បីត្រៀមរៀបចំការការពារក្តីជូនគាត់ ប្រសិនបើគាត់អាចចងចាំបានក្នុងកម្រិតគួរសម។ ទោះបីជាតុលាការរកឃើញថា ជនជាប់ចោទមានសម្បទាក្នុងការចូលរួមការជំនុំជម្រះក្តី ក៏តុលាការគប្បីបំបែកករណីគាត់ចេញពីសំណុំរឿង ០០២ ដើម្បីធានាដល់ការជំនុំជម្រះឆាប់រហ័សសម្រាប់ជនជាប់ចោទដទៃទៀត[៤៨]។

---

[៤២] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១១៩។

[៤៣] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១២៤។

[៤៤] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១២៤ ដល់ ១២៥។

[៤៥] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១២៦។

[៤៦] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១២៩ ដល់ ១៣០។

[៤៧] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០២ ដល់ ១០៣។

[៤៨] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៣។

២០ មេធាវីការពារក្ដីលោក អៀង សារី បានយល់ស្របថា តុលាការត្រូវតែបំបែកអ្នកស្រី អៀង ធីរិទ្ធ ចេញពីសំណុំរឿងនេះ ដើម្បីអនុញ្ញាតឱ្យនីតិវិធីរឿងក្ដីនេះដំណើរការទៅមុខបានឆាប់រហ័ស[៤៩]។ ការរក្សាទុកអ្នកស្រី អៀង ធីរិទ្ធ ជាភាគីក្នុងដំណើរការនីតិវិធីទាំងនេះ ទំនងជានាំឱ្យមានការរំខានដល់កាលវិភាគសវនាការ និងអាចអូសបន្លាយពេលសវនាការផ្នែកដំបូងនៃសំណុំរឿង ០០២[៥០] ទៀតផង។

២១ មេធាវីការពារក្ដីលោក នួន ជា បានអះអាងថា ការបំបែកអ្នកស្រី អៀង ធីរិទ្ធ ចេញពីសំណុំរឿង ០០២ អាចនឹងនាំឱ្យមានសំណុំរឿងពីរដែលត្រូវដំណើរការក្នុងពេលជាមួយគ្នា ដែលក្នុងនោះសវនាការទីមួយសម្រាប់ជនជាប់ចោទដែលអាចចូលរួមក្នុងរយៈពេលសវនាការទាំងស្រុង និងសវនាការទីពីរ សម្រាប់ជាប់ជនជាប់ចោទដែល "មិនមានសម្បទាគ្រប់គ្រាន់" ក្នុងការចូលរួមសវនាការ[៥១]។ សំអាងលើមូលដ្ឋាននេះ ក្រុមមេធាវីការពារក្ដីបានបញ្ជាក់ថា តុលាការត្រូវតែបំបែកអ្នកស្រី អៀង ធីរិទ្ធ និងលោក នួន ជា ចេញពីសំណុំរឿងនេះ[៥២]។

២២ មេធាវីការពារក្ដីលោក ខៀវ សំផន បានអះអាងថា គឺជាការប្រញាប់ពេក បើតុលាការបំបែកអ្នកស្រី អៀង ធីរិទ្ធ ចេញពីសំណុំរឿង ០០២ ក្នុងពេលរង់ចាំសេចក្ដីសម្រេច (រួមទាំងមុនពេលមានបណ្ដឹងសារទុក្ខ) អំពីករណីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[៥៣]។ សម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ និងការបំបែកសំណុំរឿងគឺបញ្ហាអង្គច្បាប់ពីរខុសគ្នាដែលឆ្លុះបញ្ចាំងពីសិទ្ធិខុសៗគ្នា ដូច្នេះតុលាការត្រូវតែពិចារណាករណីទាំងនេះដាច់ដោយឡែកពីគ្នា[៥៤]។

---

[៤៩] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៨៥។

[៥០] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៨៣។

[៥១] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៨៤ ដល់ ៨៥។

[៥២] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៨៥។ ចូរអានសេចក្ដីសម្រេចអំពីសម្បទារបស់លោក នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E115/3, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ដែលតុលាការរកឃើញថា លោក នួន ជា មានសម្បទាក្នុងការចូលរួមក្នុងសវនាការ)។

[៥៣] *សេចក្ដីសង្កេតលើដីកាសម្រេចស្ដីពីរយៈពេលសវនាការ ចុះថ្ងៃទី ១៩ និង ២០ ខែតុលា ឆ្នាំ ២០១១ E129/4,* ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១១ ("សេចក្ដីសង្កេតរបស់លោក ខៀវ សំផន") វាក្យខណ្ឌ ១០, ១២, ១៧។

[៥៤] សេចក្ដីសង្កេតរបស់លោក ខៀវ សំផន វាក្យខណ្ឌ ១៣, ១៥។

00753944



ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាបញ្ហានៃសម្បទាក្នុងការចូលរួមសវនាការជាមុន ហើយត្រូវរង់ចាំសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល[៥៥]។ ក្រុមមេធាវីបានអះអាងបន្ថែមទៀតថា ដើម្បីប្រយោជន៍យុត្តិធម៌ តុលាការត្រូវតែជំនុំជម្រះសមាជិកទាំងអស់ដែលរងការចោទប្រកាន់ពីបទសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ រួមគ្នា[៥៦]។ ការបំបែកសំណុំរឿងក្នុងពេលនេះ នឹងតម្រូវឲ្យមានការកែប្រែខ្លឹមសារនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងជះឥទ្ធិពលទៅលើការងារត្រៀមរៀបចំរបស់ភាគីមុនអង្គសេចក្តី និងអនុវត្តដំណើរការនីតិវិធីផងដែរ[៥៧]។ លើសពីនេះទៅទៀត ប្រសិនបើតុលាការបំបែកអ្នកស្រី អៀង ធីរិទ្ធ ចេញពីសំណុំរឿងនេះ ប៉ុន្តែក្រោយមកតាមរយៈបណ្តឹងសារទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា គាត់មានសម្បទាក្នុងការចូលរួមការជំនុំជម្រះ ពេលនោះយើងមិនច្បាស់ ថាតើតុលាការនឹងបញ្ចូលគាត់មកក្នុងដំណើការនីតិវិធីដោយរបៀបណាទេ[៥៨]។

២៣ សហព្រះរាជអាជ្ញាបានអះអាងថា ការព្រួយបារម្ភថា ស្ថានភាពរបស់អ្នកស្រី អៀង ធីរិទ្ធ អាចបណ្តាលឲ្យមានការពន្យារពេលក្នុងសំណុំរឿង ០០២ គឺជាការព្រួយបារម្ភគ្មានមូលដ្ឋានពិតប្រាកដនោះទេ[៥៩]។ ការពន្យារពេលនឹងកើតមានគ្រប់ពេលវេលាដោយសារតែជនជាប់ចោទទាំងអស់

---

[៥៥] សេចក្តីសង្កេតរបស់លោក ខៀវ សំផន វាក្យខណ្ឌ ៣០ (ដែលបានកត់សម្គាល់ថា ការខកខានមិនបានអនុវត្តបែបនេះគឺការបំពានលើសមត្ថកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល)។

[៥៦] សេចក្តីសង្កេតរបស់លោក ខៀវ សំផន វាក្យខណ្ឌ ៣៤។

[៥៧] សេចក្តីសង្កេតរបស់លោក ខៀវ សំផន វាក្យខណ្ឌ ៣៩។

[៥៨] សេចក្តីសង្កេតរបស់លោក ខៀវ សំផន វាក្យខណ្ឌ ៤៦-៤៧, ៥០ (ដែលបានកត់សម្គាល់ថា ការបើកសវនាការឡើងវិញ ដើម្បីស្តាប់សាក្សីទាំងអស់ដែលបានផ្តល់សក្ខីកម្មក្នុងពេលអវត្តមានរបស់អ្នកស្រី អៀង ធីរិទ្ធ នឹងមិនបម្រើគោលការណ៍សន្សំសំចៃធនធានតុលាការទេ ហើយសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលរបស់លោក ខៀវ សំផន មិនគប្បីត្រូវបានពន្យារពេលរហូតដល់ប្រាំខែដែលរង់ចាំសេចក្តីសម្រេចលើបណ្តឹងសារទុក្ខអំពីសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការឡើយ)។

[៥៩] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១១៧។

00753945



មានវ័យចាស់ជរា ហើយពួកគាត់អាចស្នើសុំឱ្យតុលាការផ្អាកដំណើរការសវនាការ ដោយផ្អែកលើមូលហេតុសុខភាពរបស់គាត់[៦០]។

២៤ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អង្គជំនុំជម្រះមានសិទ្ធិសម្រេច ថាតើខ្លួនត្រូវ ឬមិនត្រូវបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីសំណុំរឿង ០០២ ដើម្បីជាប្រយោជន៍ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចបញ្ចប់ការជំនុំជម្រះជនជាប់ចោទដទៃទៀតបានឆាប់រហ័ស[៦១]។

## ៤. សំអាងហេតុ

### ៤.១ ច្បាប់ដែលអនុវត្ត

២៥ វិធាន ៣២ នៃវិធានផ្ទៃក្នុងបានចែងថា ក្នុងគោលបំណងដើម្បីបញ្ជាក់ថា ជនជាប់ចោទមានសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តអាចចូលរួមក្នុងការជម្រះក្តី អង្គជំនុំជម្រះអាចបង្គាប់ឱ្យជនជាប់ចោទទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ វិកលចរិត ចិត្តសាស្ត្រ ដោយអ្នកជំនាញ។ គោលការណ៍ដែលត្រូវបានបង្កើតក្នុងលំដាប់អន្តរជាតិបានចង្អុលបង្ហាញថា៖

> ទោះបីជាវាទាក់ទងដោយគ្មានសង្ស័យទៅនឹងលក្ខខណ្ឌខាងផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទក្តី ក៏សម្បទា ឬសមត្ថភាពក្នុងការចូលរួមការជម្រះក្តីគឺជាបញ្ហា ដែលមិនកម្រិតត្រឹមតែការបង្ហាញភស្តុតាងថាតើជនជាប់ចោទមាន ឬគ្មានជំងឺដែលលើកឡើងនោះទេ [...] ប៉ុន្តែគប្បីត្រូវឈានទៅដល់ការកំណត់ថាតើ [ជនជាប់ចោទ] អាចអនុវត្តសិទ្ធិរបស់ខ្លួន ដោយមានប្រសិទ្ធភាពក្នុងដំណើរការនីតិវិធីប្រឆាំងនឹងខ្លួនដែរ ឬទេ[៦២]។

---

[៦០] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១១៧។

[៦១] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១៣១។

[៦២] *រដ្ឋអាជ្ញា ទល់នឹង Pavle Strugar* សេចក្តីសម្រេចលើបណ្តឹងសុំបញ្ចប់ដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ IT-01-42-T ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៤ ("សេចក្តីសម្រេច *Strugar*") វាក្យខណ្ឌ ៣៥។ ចូរអានមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង អ.វ.ត.ក") និងមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") ដែលចែងថា ("ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើ

២៦ ចំពោះបញ្ហាសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានការពារនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ICTY (ដែលមានខ្លឹមសារដូចគ្នានឹងសិទ្ធិដែលបានចែងក្នុងក្រមខណ្ឌច្បាប់ អ.វ.ត.ក[63]) ក្នុងរឿងក្តី *Strugar* តុលាការបានសម្រេចថា វិធីសាស្ត្រសមស្របដែលត្រូវយកមកប្រើដើម្បីកំណត់សម្បទាក្នុងការចូលរួមការជម្រះក្តី គឺត្រូវវាយតម្លៃលើ៖

- សមត្ថភាពឆ្លើយតបទៅនឹងបទចោទ
- សមត្ថភាពយល់ដឹងអំពីលក្ខណៈនៃការចោទប្រកាន់
- សមត្ថភាពយល់ដឹងអំពីការប្រព្រឹត្តទៅនៃដំណើរការនីតិវិធី
- សមត្ថភាពយល់ដឹងអំពីសេចក្តីពិស្តារនៃភស្តុតាង
- សមត្ថភាពណែនាំមេធាវីការពារក្តីរបស់ខ្លួន
- សមត្ថភាពយល់ដឹងពីផលវិបាកនៃដំណើរការនីតិវិធី និង
- សមត្ថភាពធ្វើសក្ខីកម្មរបស់ជនជាប់ចោទ[64]។

---

មានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ [...] គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ)។

[63] ចូរអានមាត្រា ១៣ នៃកិច្ចព្រមព្រៀង ដែលយោងទៅរកមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ ចូរអានផងដែរនូវ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា ("អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស [...] ដោយការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ [...] មាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ដែលចែងពីសិទ្ធិទទួលព័ត៌មាន អំពីប្រភេទនៃការចោទប្រកាន់ចំពោះខ្លួន សិទ្ធិមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន សិទ្ធិទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង សិទ្ធិទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយពេល សិទ្ធិពិនិត្យភស្តុតាងដាក់បន្ទុកលើខ្លួន សិទ្ធិមានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា)។

[64] សេចក្តីសម្រេច *Strugar* វាក្យខណ្ឌ ៣៦ (ត្រូវបានចែងយោងវាក្យខណ្ឌ ២ នៃដីកាចាត់តាំងអ្នកជំនាញចិត្តសាស្ត្រ) ចូរអានសាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* *Strugar* របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-01-42-A) ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Strugar*") វាក្យខណ្ឌ ៥៥ ("ក្នុងការវាយតម្លៃសម្បទារបស់ *Strugar* ក្នុងការចូលរួមការជំនុះជម្រះក្តី អង្គជំនុំជម្រះសាលាដំបូងបានកំណត់ត្រឹមត្រូវអំពីបញ្ជីរាយសិទ្ធិដែលចាំបាច់សំរាប់កំណត់សម្បទារបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះ")។ ចូរអានរឿងក្តី*អគ្គរដ្ឋអាជ្ញារងខាងបទល្មើសធ្ងន់ធ្ងរ ទល់នឹង* *Josep Nahak* ការរកឃើញ និងដីកាសម្រេចលើសមត្ថភាពរបស់ *Nahak* ក្នុងការចូលរួមការជំនុំជម្រះក្តីក្រុមប្រឹក្សាតុលាការ

២៧ បទដ្ឋានដែលត្រូវយកមកអនុវត្ត ក្នុងការកំណត់សម្បទាក្នុងការចូលរួមការជំនុំជម្រះក្ដី "គឺការចូលរួមដែលមានអត្ថន័យ ដែលអនុញ្ញាតឱ្យជនជាប់ចោទអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ខ្លួនក្នុងកម្រិតមួយ ដែលជនជាប់ចោទអាចចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងការជំនុំជម្រះក្ដីលើរូបខ្លួន និងមានការយល់ដឹងសារៈសំខាន់នៃដំណើរការនីតិវិធីនានា[៦៥]។ ហេតុដូច្នេះ ដើម្បីកំណត់អំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះក្ដី គឺត្រូវពិនិត្យមើលជារួមពីអាកប្បកិរិយាទូទៅ និងក្នុងលក្ខណៈសមហេតុផលមួយ ពោល គឺ ស្ថិតនៅកម្រិតមួយដែលអាចឱ្យជនជាប់ចោទ អាចចូលរួមក្នុងដំណើរការនីតិវិធី (ក្នុងករណីខ្លះត្រូវមានជំនួយ) និងអនុវត្តសិទ្ធិទាំងឡាយបានយ៉ាងពេញលេញបាន[៦៦]។

២៨ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់ថែមទៀតថា គេមិនអាចរំពឹងឱ្យជនជាប់ចោទដែលតំណាងដោយមេធាវី មានការយល់ដឹងអំពីសម្ភារៈ/វត្ថុតាងក្នុងរឿងក្ដីរបស់ខ្លួនដូចមេធាវីដែលមានការអប់រំ និងបទពិសោធន៍ក្នុងវិស័យច្បាប់ទេ[៦៧]។ សូម្បីតែបុគ្គលដែលមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្តក៏ដោយ ក៏ត្រូវការជំនួយខាងផ្លូវច្បាប់យ៉ាងខ្លាំង បើខ្លួនមិនបានទទួលការអប់រំច្បាប់ថ្នាក់ខ្ពស់ និងមុខជំនាញពាក់ព័ន្ធទេ ជាពិសេសករណីទាំងឡាយដែលមានអង្គហេតុ និងបញ្ហាអង្គច្បាប់ស្មុគស្មាញ ដូចរឿងក្ដីដែលជំនុំជម្រះដោយសាលាក្ដីអន្តរជាតិនានា។ អាស្រ័យហេតុនេះ អ្វីដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការសម្រេចថា ជនជាប់មានសម្បទាចូលរួមក្នុងការជំនុំជម្រះក្ដី គឺជា "បទដ្ឋានស្ដីពីសមត្ថភាពទូទៅដែលអនុញ្ញាតឱ្យមានការចូលរួមក្នុងការជំនុំជម្រះក្ដីប្រកបដោយអត្ថន័យ ក្នុងករណីដែលជនជាប់ចោទមានមេធាវីតំណាងត្រឹមត្រូវ"[៦៨]។ វត្តមានរបស់មេធាវីការពារក្ដីអាចផ្ដល់លទ្ធភាពឱ្យជនជាប់ចោទអាចយល់ដឹងពីភស្តុតាង ដំណើរ-ការនីតិវិធី និងផលវិបាកនៃដំណើរការនីតិវិធីបានគ្រប់គ្រាន់។ ប៉ុន្តែក្នុងករណីពិសេស វត្តមានរបស់

---

ពិសេសសម្រាប់បទល្មើសធ្ងន់ធ្ងរ (ទីមូរខាងកើត) សំណុំរឿងលេខ 01A/2004 ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥ ("សេចក្ដីសម្រេច Nahak") វាក្យខណ្ឌ ៥៦។

[៦៥] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ Strugar វាក្យខណ្ឌ ៥៥។

[៦៦] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ Strugar វាក្យខណ្ឌ ៥៥។

[៦៧] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ Strugar វាក្យខណ្ឌ ៦០។

[៦៨] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ Strugar វាក្យខណ្ឌ ៦០។

មេធាវី “អាចបំពេញបន្ថែមយ៉ាងគ្រប់គ្រាន់ទៅលើរាល់ការខ្វះចន្លោះនៃសមត្ថភាពដែលពាក់ព័ន្ធ” ប៉ុន្តែការប្រើមេធាវី “តម្រូវឱ្យជនជាប់ចោទមានសមត្ថភាពអាចណែនាំមេធាវីប្រកបដោយប្រសិទ្ធភាពសម្រាប់គោលបំណងនេះ”[៦៩]។ ទោះបីជាខ្លួនមានមេធាវីតំណាងក្តី ប្រសិទ្ធភាពនៃការអនុវត្តសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ “អាចនឹងត្រូវបានរារាំង ឬត្រូវបានបដិសេធចោល ប្រសិនបើសមត្ថភាពខាងផ្លូវកាយ និងសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ ជាពិសេសសមត្ថភាពក្នុងការយល់ដឹង ត្រូវបានបំផ្លាញដោយសារជំងឺផ្លូវចិត្ត ឬជំងឺផ្នែកប្រព័ន្ធប្រសាទ[៧០]។ ជាក់ស្តែង “ក្នុងករណីនីមួយៗ ជនជាប់ចោទត្រូវតែមាន [សមត្ថភាព] ក្នុងកម្រិតគ្រប់គ្រាន់ ដែលផ្តល់លទ្ធភាពឱ្យមេធាវីការពារក្តីអាចការពារជនជាប់ចោទបាន”[៧១]។

២៩ តាមរយៈការវាយតម្លៃលើសម្ភារៈ/ឯកសារ និងកត្តាពាក់ព័ន្ធទាំងអស់ដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងត្រូវតែមានព័ត៌មានគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន[៧២]។ ដើម្បីកំណត់ពីសម្បទាក្នុងការចូលរួមការជំនុំជម្រះក្តី អង្គជំនុំជម្រះក៏អាចពឹងផ្អែកលើការសង្កេតផ្ទាល់របស់ខ្លួនលើជនជាប់ចោទក្នុងអំឡុងពេលនៃដំណើរការនីតិវិធីផងដែរ[៧៣]។

---

[៦៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ Strugar កថាខណ្ឌ ២២។

[៧០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ Strugar កថាខណ្ឌ ២៣។

[៧១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ Strugar កថាខណ្ឌ ២៤។

[៧២] *Edward Karemera, Matthieu Ngirumpaste & Joseph Nzirorera* ***ទល់នឹង រដ្ឋអាជ្ញា*** សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការបំបែក Matthieu Ngirumpaste ចេញពីសំណុំរឿង អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR សំណុំរឿងលេខ ICTR-98-44-AR73.16, ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៩ វាក្យខណ្ឌ ១៩ (ដែលកត់សម្គាល់ថា “ក្នុងការអនុវត្ត អង្គជំនុំជម្រះពិចារណាជាទូទៅលើមតិយោបល់របស់អ្នកជំនាញទាំងឡាយ មុននឹងធ្វើសេចក្តីសម្រេចលើនីតិវិធីដ៏សំខាន់ ដែលកើតចេញពីស្ថានភាពវេជ្ជសាស្ត្ររបស់ជនជាប់ចោទ ដែលអាចជះឥទ្ធិពលទៅលើដំណើរការជំនុំជម្រះ”។)

[៧៣] សេចក្តីសម្រេច Strugar វាក្យខណ្ឌ ៥១ (ដែលពិចារណាថា យោបល់របស់ជនជាប់ចោទគឺ “មានលក្ខណៈប្រមូលផ្តុំ ភាពពាក់ព័ន្ធ មានរចនាសម្ព័ន្ធត្រឹមត្រូវ និងភាពយល់ដឹងទូលំទូលាយ”, លទ្ធភាពជាក់ស្តែងរបស់ជនជាប់ចោទក្នុងការយល់ដឹងពីភស្តុតាង ការកត់ត្រា ការយកចិត្តទុកដាក់ និងការប្រតិកម្មទៅនឹងបញ្ហាដែលមានផលប្រយោជន៍ខ្លាំងដល់គាត់ កិរិយាតាមដានដំណើរការនីតិវិធី និងការលើកពីការព្រួយបារម្ភនៅពេលដែលគាត់មិនអាចធ្វើបាន (ឧទាហរណ៍ ដោយសារបញ្ហាបច្ចេកទេស)) ចូរអានសាលក្រម រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Florencio Tacaqui សំណុំរឿងលេខ ២០/២០០១ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០០៤ ទំព័រ ៨ ដល់ ៩ និងសេចក្តីសម្រេច *Nahak* វាក្យខណ្ឌ ១២០ ផងដែរ។

៣០ យុត្តិសាស្ត្ររបស់តុលាការ ICTY បានកត់សម្គាល់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង "ត្រូវការអង្គហេតុខាងវេជ្ជសាស្ត្រ ដើម្បីសម្រេចលើបញ្ហាផ្លូវច្បាប់មួយចំនួន។ [ទោះបីជាយ៉ាងណាក្តី] ទាក់ទិននឹងវិធីសាស្ត្រជាក់លាក់ [ដែលអ្នកជំនាញត្រូវយកមកប្រើក្នុងការវាយតម្លៃជនជាប់ចោទ] ដែលរួមបញ្ចូលទាំងប្រភេទតេស្តខាងវេជ្ជសាស្ត្រដែលត្រូវយកមកអនុវត្ត [...] នេះជាបញ្ហាដែលត្រូវកំណត់ដោយអ្នកជំនាញដែលទទួលការចាត់តាំងពីតុលាការ"[៧៤]។ ចំណុចទុសគ្នាបន្តិចបន្តួចរវាងរបាយការណ៍ ឬវិការៈនានាដែលមិនប៉ះពាល់ដល់សេក្តីសន្និដ្ឋានទូទៅអំពីសម្បទាក្នុងការចូលរួមការជំនុំជម្រះ មិនមែនជាកត្តាតម្រូវឱ្យមានការចាត់តាំងអ្នកជំនាញបន្ថែមទេ[៧៥]។

## ៤.២ <u>គុណវុឌ្ឍិរបស់អ្នកជំនាញ</u>

៣១. សាស្ត្រាចារ្យ A. John Campbell ជាអ្នកជំនាញវេជ្ជសាស្ត្រផ្នែកព្យាបាលមនុស្សចាស់ (មើលថែទាំមនុស្សចាស់)[៧៦]។ ជំនាញរបស់គាត់មានរួមទាំងផ្នែកជំងឺវង្វេងវង្វាន់ស្មារតី និងជំងឺ Alzheimer។ ជំនាញរបស់គាត់ត្រូវបានទទួលស្គាល់ទាំងក្នុងប្រទេសនូវែលសេឡង់ ដែលជាប្រទេសកំណើត

---

[៧៤] រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić and Franko Simatović សេចក្តីសម្រេចលើសំណើបន្ទាន់របស់មេធាវីការពារក្តី សុំឱ្យដាក់របាយការណ៍អ្នកជំនាញវេជ្ជសាស្ត្រ ចិត្តសាស្ត្របន្ថែម និងសេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តី សុំកោសលប់របាយការណ៍វេជ្ជសាស្ត្រ, សំណុំរឿងលេខ IT-03-69-PT ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០៩ វាក្យខណ្ឌ ១៥ (ដែលបានកត់សម្គាល់ថា "អង្គជំនុំជម្រះរំពឹងថារាល់វេជ្ជបណ្ឌិតរាយការណ៍ ប្រើប្រាស់រាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការវិភាគរោគសញ្ញានៃជនជាប់ចោទនៅក្នុងរបាយការណ៍របស់ខ្លួន ទៅតាមជំនាញឯកទេសរៀងៗខ្លួន")។

[៧៥] ទោះបីជាការពិនិត្យបន្ថែមត្រូវបានបង្គាប់ឱ្យធ្វើឡើង នៅពេលដែលមានភាពមិនស៊ីសង្វាក់គ្នាគួរឱ្យកត់សម្គាល់រវាងទស្សនៈរបស់អ្នកជំនាញវេជ្ជសាស្ត្រ បន្ទាប់ពីពួកគាត់បានឈានទៅរកការសន្និដ្ឋានយ៉ាងណាក្តី ក៏គេត្រូវបានមានហេតុផលគ្រប់គ្រាន់ដើម្បីយកមកធ្វើជាយុត្តិកម្មក្នុងសុំឱ្យមានការស៊ើបអង្កេត (*សូមមើលផងដែរ ឧទាហរណ៍ ព្រះរាជអាជ្ញា ទល់នឹង Vladimir Kovačević* សេចក្តីសម្រេចជាសាធារណៈស្តីពីសម្បទាក្នុងការឆ្លើយតបទៅនឹងបទចោទ និងការចូលរួមក្នុងការជំនុំជម្រះក្តី អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY សំណុំរឿងលេខ IT-01-42/2-I ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ១៧។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ពាក់ព័ន្ធនឹងការចាត់តាំងអ្នកជំនាញ ឯកសារ D54/V/6 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៣២-៣៤)។

[៧៦] សេចក្តីសង្ខេបស្តីពីគុណវុឌ្ឍិរបស់អ្នកជំនាញ សាស្ត្រាចារ្យ CAMPBELL E62.1 ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១០។

របស់គាត់ និងនៅលើឆាកអន្តរជាតិ[៧៧]។

៣២. អ្នកជំនាញផ្នែកវិកលវិទ្យា ដែលត្រូវបានអង្គជំនុំជម្រះចាត់តាំង គឺជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រវិកលវិទ្យា[៧៨]។ លោកវេជ្ជបណ្ឌិត ហួត លីនណា និង កើត ឈុនលី គឺជាវេជ្ជបណ្ឌិតមានគុណវុឌ្ឍិផ្នែកវិកលវិទ្យា និងធ្វើការនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅរាជធានីភ្នំពេញ[៧៩]។ វេជ្ជបណ្ឌិត Calvin FONES SOON LENG គឺជាគ្រូពេទ្យឯកទេសផ្នែកវិកលវិទ្យា ដែលកំពុងធ្វើការផ្នែកនេះនៅក្នុងប្រទេសសិង្ហបុរី និងបានបោះពុម្ពផ្សាយឯកសារផ្នែកវិកលវិទ្យាមនុស្សចាស់[៨០]។ ចុងក្រោយគឺវេជ្ជបណ្ឌិត Seena FAZEL ជាសាស្ត្រាចារ្យជាន់ខ្ពស់ខាងរោគវិនិច្ឆ័យផ្នែកវេជ្ជសាស្ត្រវិកលវិទ្យានៅឯសាកលវិទ្យាល័យ Oxford និងបានបោះពុម្ពផ្សាយឯកសារផ្នែកជំងឺវង្វេងវង្វាន់ស្មារតី ការចុះខ្សោយសតិបញ្ញា និងការវាយតម្លៃខាងសមត្ថភាព[៨១]។

## ៤.៣ របាយការណ៍ និងសក្ខីកម្មរបស់សាស្ត្រាចារ្យ CAMPBELL

៣៣. នៅក្នុងរបាយការណ៍ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ របស់គាត់ សាស្ត្រាចារ្យ CAMPBELL រកឃើញថា "លោកស្រី អៀង ធីរិទ្ធ មានការចុះខ្សោយសតិបញ្ញាជាទូទៅ ជាពិសេសនៅក្នុងផ្នែកចងចាំ ការនិយាយស្តី ការបកស្រាយ ឬការពន្យល់ និងមុខងារខួរក្បាលខាងលើផ្នែកខាងមុខ ដែលស្របគ្នាជាមួយនឹងជំងឺវង្វេងវង្វាន់ស្មារតី"[៨២]។ គាត់បានសន្និដ្ឋានថា "លោកស្រី អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់លទ្ធភាពក្នុងការយល់អំពីសំណួរ ការអនុវត្តតាមការណែនាំ ការរំឭកឡើងវិញអំពីហេតុការណ៍នានា ការផ្ចង់អារម្មណ៍ និងការរក្សាការគិតឱ្យស៊ី

---

[៧៧] ប្រតិចារឹកថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ កថាខណ្ឌ ៣៤-៣៥ ៣៨-៣៩។

[៧៨] ដីកាចាត់តាំងអ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ១។

[៧៩] ប្រវត្តិរូបរបស់វេជ្ជបណ្ឌិត កើត ឈុនលី E111.1 និងប្រវត្តិរូបរបស់វេជ្ជបណ្ឌិត ហួត លីនណា E111.2។ លោកវេជ្ជបណ្ឌិត ហួត លីនណា បានសិក្សាចប់ថ្នាក់ក្រោយឧត្តមសិក្សាផ្នែកវេជ្ជសាស្ត្រវិកលវិទ្យា (ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ទំព័រទី ៧៩)។

[៨០] ប្រវត្តិរូបរបស់វេជ្ជបណ្ឌិត Calvin FONES SOON LENG, E111.3 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១១។

[៨១] ប្រវត្តិរូបរបស់វេជ្ជបណ្ឌិត FAZEL, E111.4។

[៨២] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ២៨។

សង្វាក់គ្នា"[៨៣]។ គាត់ពិពណ៌នាជំងឺវង្វេងវង្វាន់ស្មារតីថាជា "ការចុះខ្សោយរុំរ៉ៃ និងវិវឌ្ឍទៅរកភាពធ្ងន់ធ្ងរជាលំដាប់នៃមុខងារសតិបញ្ញា (រួមទាំងការចងចាំ) ដែលជាទូទៅបណ្តាលមកពីជំងឺ Alzheimer"[៨៤]។ សាស្ត្រាចារ្យ CAMPBELL បានកត់សម្គាល់បន្ថែមទៀតថា លទ្ធផលនៃការស្កេនខួរក្បាលលោកស្រី អៀង ធីរិទ្ធ (CT Head Scan) នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១១ ដែល "បានបង្ហាញឲ្យឃើញនូវការរួញស្វិតនៃខួរក្បាលជាលក្ខណៈទូទៅមួយ ស្របគ្នាទៅនឹងវ័យ ឬជំងឺ Alzheimer" នោះ គឺមានមានភាពស៊ីសង្វាក់គ្នាទៅនឹងការវិភាគរោគសញ្ញានេះ[៨៥]។

៣៤. សាស្ត្រាចារ្យ CAMPBELL ក៏បានកត់សម្គាល់ឃើញថា បន្ទាប់ពីមានការប្រេះស្រាំឆ្អឹងត្រគាកនៅក្នុងខែ មករា ឆ្នាំ ២០០៦ រួចមក ជនជាប់ចោទត្រូវទទួលការវះកាត់ព្យាបាល។ កំណត់ហេតុវេជ្ជសាស្ត្រ គូសបញ្ជាក់ថា ជនជាប់ចោទមានរោគសញ្ញាវង្វេងវង្វាន់ វិលមុខ និងសម្រាន្តមិនលក់។ អ្នកជំនាញទាំងអស់សុទ្ធតែបានយល់ស្របគ្នាថា លោកស្រី អៀង ធីរិទ្ធ នៅពេលនេះ ទំនងជាមានជំងឺវង្វេងវង្វាន់ក្នុងរយៈពេលខ្លីមួយនៅក្រោយពេលវះកាត់ ដែលករណីនេះជាប្រការដាច់ដោយឡែកគ្នាមួយ មិនពាក់ព័ន្ធទៅនឹងស្ថានភាពចុះដុនដាបនាពេលបច្ចុប្បន្នរបស់គាត់នោះទេ"[៨៦]។

---

[៨៣] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៣៤។

[៨៤] ប្រតិចារិក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៣៥-៣៦ ១១៦។ ប្រតិចារិក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១១ ៤៦។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៩ (ដែលពន្យល់បន្ថែមថា ជាបច្ច័យនៃស្ថានភាពបែបនេះ ជាទូទៅការបាត់បងការចងចាំចាប់ផ្តើមកើតមានដោយការមិនអាចរំឭកព្រឹត្តិការណ៍ថ្មីៗឡើងវិញបាន និងដែលកាន់តែវិវឌ្ឍទៅរកភាពដុនដាប និងប៉ះពាល់ដល់ការចងចាំរយៈពេលយូរផងដែរ)។

[៨៥] របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញព្យាបាលមនុស្សចាស់ កថាខណ្ឌ ៧។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១៣០ ១៣៤។ ប្រតិចារិក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៤ និងរបាយការណ៍អ្នកជំនាញព្យាបាលមនុស្សចាស់ កថាខណ្ឌ ៣១។

[៨៦] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៩ និងប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ២៣ ៧០-៧១។ *សូមមើលផងដែរ* របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២៦ (ដោយយល់ស្របទៅនឹងសាស្ត្រាចារ្យ CAMPBELL ដែលថាលោកស្រី អៀង ធីរិទ្ធ ទំនងជាមានជំងឺវង្វេងវង្វាន់ក្រោយពេលវះកាត់ក្នុងឆ្នាំ ២០០៦ និងថាប្រការនេះពុំបានបង្ហាញជាភ័ស្តុតាងបញ្ជាក់ឲ្យឃើញថា លោកស្រីមានជំងឺវង្វេងវង្វាន់ស្មារតីដែលរកឃើញតាមរយៈការធ្វើរោគវិនិច្ឆ័យ ឬវិបល្លាសកម្រិតធ្ងន់ដទៃទៀតនោះទេ)។ ប្រិតចារិក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១២៩។ ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៧០-៧១ និង ប្រតិចារិក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៨៨ (ដោយកត់សម្គាល់ឃើញថា ការ

៣៥. បន្ទាប់ពីពិនិត្យលោកស្រី អៀង ធីរិទ្ធ សាស្ត្រាចារ្យ CAMPBELL សន្និដ្ឋានថា ការចងចាំរបស់ជនជាប់ចោទក្នុងពេលបច្ចុប្បន្ននេះមានការចុះខ្សោយជាមធ្យម និងការចងចាំអំពីរឿងរ៉ាវអតីតកាលរបស់គាត់មានភាពស្រពិចស្រពិល និងភាគច្រើនមិនត្រឹមត្រូវទេ[៨៧]។ គាត់បានកត់សម្គាល់ទៀតថា ជាឧទាហរណ៍ លោកស្រីមិនដឹងពេលវេលាត្រឹមត្រូវ និងមានបញ្ហាលំបាកក្នុងការនឹកឃើញរឿងរ៉ាវលម្អិតអំពីពេលដែលគាត់ធ្លាប់រស់នៅក្នុងប្រទេសបារាំង។ លោកស្រី អាចផ្តល់ព័ត៌មានលម្អិតបានតិចតួចប៉ុណ្ណោះ ពាក់ព័ន្ធនឹងសាច់ញាតិផ្ទាល់របស់លោកស្រី និងភាគច្រើននៃព័ត៌មានដែលគាត់ផ្តល់ឱ្យគឺមិនត្រឹមត្រូវទេ។ ឧទាហរណ៍ ដូចជាថាលោកស្រីមិនមានកូនខ្លួនឯងទេ ប៉ុន្តែបានសុំកូនគេយកមកចិញ្ចឹម[៨៨]។ លោកស្រី អៀង ធីរិទ្ធ មានបញ្ហាក្នុងការយល់ដឹងអំពីគោលបំណងក្នុងការពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យ CAMPBELL[៨៩]។ សាស្ត្រាចារ្យ CAMPBELL បានកត់សម្គាល់បន្ថែមទៀតថា មានពេលខ្លះលោកស្រី អៀង ធីរិទ្ធ មានអារម្មណ៍ច្របូកច្របល់ ឬវង្វេងនៅក្នុងអគារមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ទោះបីជាទីនោះជាកន្លែងតូចមួយដែលលោកស្រីស្គាល់រួចហើយយ៉ាងណាក៏ដោយ[៩០]។

៣៦. ក្នុងពេលវាយតម្លៃ សាស្ត្រាចារ្យ CAMPBELL បានដាក់តេស្ត MMSE ដែលជាតេស្តគេប្រើជាទូទៅមួយ ដើម្បីវាយតម្លៃការចុះខ្សោយផ្នែកសតិបញ្ញា។ លទ្ធផលតេស្តបានបង្ហាញថា ជនជាប់ចោទមិនអាចផ្តល់ចម្លើយតបត្រឹមត្រូវទៅតាមសំណួរដែលបានចោទសួរ ដូចជាឈ្មោះអគារដែលលោកស្រីស្នាក់នៅ និងអាយុរបស់លោកស្រី[៩១]។ លោកស្រីអាចដាក់លេខលើមុខ

---

រវើរវាយរបស់លោកស្រី ត្រូវបានព្យាបាលនៅពេលនោះរួចហើយ និងថា ជនជាប់ចោទពុំមានរោគសញ្ញាផ្លូវចិត្តអ្វីបន្ថែមផ្សេងទៀតនោះទេ)។

[៨៧] ប្រតិចារិក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១៣០ ១៣៦ ១៣៧។ *សូមមើលផងដែរ* របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១៧ ១៩ និងរបាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៦។

[៨៨] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១៩។

[៨៩] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១៥។

[៩០] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១៣។

[៩១] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១៧ ២៤ ២៥។

នាឡិកាបាន ប៉ុន្តែមិនអាចគូរទ្រនិចនាឡិកាបានទេ[៥២]។

៣៧. ទោះបីជាសាស្ត្រាចារ្យ CAMPBELL យល់ឃើញថា ការកាត់បន្ថយការប្រើប្រាស់ឱសថសម្រួលស្ថានភាពផ្លូវចិត្តដែលលោកស្រី អៀង ធីរិទ្ធ កំពុងប្រើប្រាស់ ប្រហែលជាអាចធ្វើឱ្យមុខងារសតិបញ្ញារបស់គាត់មានភាពប្រសើរឡើងខ្លះយ៉ាងណាក្តី ក៏លទ្ធផលនៃការបន្ថយឱសថនេះទំនងជាមិនផ្តល់ភាពប្រសើរឡើងគួរឱ្យកត់សម្គាល់អ្វីនោះដែរ[៥៣]។ ឱសថសម្រួលស្ថានភាពផ្លូវចិត្តពីរមុខត្រូវបានកាត់បន្ថយបន្តិចម្តងៗ នៅមុនសាស្ត្រាចារ្យ CAMPBELL វាយតម្លៃជនជាប់ចោទសារជាថ្មី ប៉ុន្តែវាមិនបានធ្វើឱ្យមុខងារសតិបញ្ញារបស់លោកស្រី អៀង ធីរិទ្ធ មានភាពប្រសើរនោះទេ[៥៤]។ សាស្ត្រាចារ្យ CAMPBELL បានគូសបញ្ជាក់បន្ថែមទៀតថា គេអាចពិចារណាសាកល្បងប្រើប្រាស់ឱសថ donepezil ដើម្បីព្យាបាលជំងឺ Alzheimer ផងដែរ[៥៥]។ ប៉ុន្តែ គាត់បានមានប្រសាសន៍ដាស់តឿនថា ឱសថនេះមានប្រសិទ្ធភាពលើមនុស្សតែមួយភាគបីប៉ុណ្ណោះ និងថាការប្រសើរឡើងជាងមុនណាមួយ "ប្រសិនបើមានមែន ក៏មានត្រឹមតិចតួចប៉ុណ្ណោះ"[៥៦]។

៣៨. ទោះបីជាលោកបានកត់សម្គាល់ថា សាស្ត្រាចារ្យ ការ ស៊ុនបូណាត និងសាស្ត្រាចារ្យ Brinded

---

[៥២] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ២៥។

[៥៣] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៣៥ ៤៤។

[៥៤] គិតមកត្រឹមថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ លោកស្រី អៀង ធីរិទ្ធ កំពុងប្រើប្រាស់ឱសថ clonazepam កម្រិត ១ មិល្លីក្រាម quetiapine កម្រិត ១០០ មិល្លីក្រាមប្រចាំថ្ងៃ និងឱសថ bromazepam ពីរទៅបួនដងក្នុងមួយសប្តាហ៍ (របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៤២)។ លោកស្រីបានឈប់ប្រើឱសថ clonazepam និង bromazepam ទាំងស្រុង និងបានចាប់ផ្តើមបន្ថយកម្រិតឱសថ quetiapine នៅពាក់កណ្តាលខែ សីហា ឆ្នាំ ២០១១ (របាយការណ៍ស្តីពីកិច្ចប្រជុំតាមរយៈ សន្និសីទវីដេអូ ជាមួយវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យកាល់ម៉ែត ដែលមើលថែទាំលោកស្រី អៀង ធីរិទ្ធ ឯកសារ E62/3/6/4/.1 ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ ប្រតិចារឹកថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៦១)។ នៅពេលអ្នកជំនាញផ្នែកវិកលវិទ្យាសម្ភាសលោកស្រី អៀង ធីរិទ្ធ ឱសថ quetiapine ត្រូវបានកាត់បន្ថយមកត្រឹមពាក់កណ្តាល (ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១១០)។ *សូមមើលផងដែរ* របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៦ និងប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១១៩ ១២៤។

[៥៥] របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៨(ii)។

[៥៦] របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៨(ii) (កត់សម្គាល់បន្ថែមទៀតថា ប្រសិនបើមានផលប៉ះពាល់ពីការប្រើប្រាស់ឱសថនេះ គេនឹងត្រូវបញ្ឈប់វា)។

បានពិនិត្យលោកស្រី អៀង ធីរិទ្ធ នៅក្នុងឆ្នាំ ២០០៩ និងបានសន្និដ្ឋានថា លោកស្រីមានបញ្ហាចុះខ្សោយសតិបញ្ញាតិចតួចយ៉ាងណាក្ដី ក៏សាស្ត្រាចារ្យ CAMPBELL យល់ឃើញថា ស្ថានភាពលោកស្រី អៀង ធីរិទ្ធ មានភាពវិវឌ្ឍចាប់តាំងពីពួកគាត់បានពិនិត្យលោកស្រីរួចមក[៩៧]។ ទោះបីជាមានមតិលើកឡើង ដោយប៉ុនប៉ងចាត់គ្រប់វិធានការណ៍ ដើម្បីធ្វើឲ្យមុខងារសតិបញ្ញាប្រសើរឡើងវិញយ៉ាងណាក៏ដោយ ក៏ប៉ុន្តែគេមិនអាចនិយាយឲ្យដាច់ណាត់បានថា លោកស្រី អៀង ធីរិទ្ធ នឹងអាចចូលរួមក្នុងសវនាការបានឡើយ។ សាស្ត្រាចារ្យ CAMPBELL យល់ឃើញថា កំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬវិធីសាស្ត្រដទៃទៀត ដើម្បីជួយដល់ការរំឭកឲ្យនឹកឃើញឡើងវិញណាមួយនឹងមិនទំនងជាអាចជួយដោះស្រាយបញ្ហានៃការចុះខ្សោយការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ បានទេ[៩៨]។ គាត់ក៏យល់ឃើញផងដែរថា លោកស្រីមិនបានធ្វើពុតជាមានជំងឺវង្វេងវង្វាន់ស្មារតីនោះទេ[៩៩]។

៣៩. ជាលទ្ធផល សាស្ត្រាចារ្យ CAMPBELL បានសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ នឹងមានបញ្ហាលំបាកក្នុងការយល់អំពីលក្ខណៈនៃបទចោទមកលើរូបគាត់ ឬបញ្ហាលំបាកក្នុងការតាមដានកិច្ចដំណើរការនីតិវិធី បញ្ហាលំបាកក្នុងការយល់ដឹងអំពីចម្លើយរបស់សាក្សីដែលរៀបរាប់អំពីព្រឹត្តិការណ៍ដែលកើតឡើង ៣៥ ឆ្នាំមុន និងការណែនាំដល់មេធាវីការពារក្ដីរបស់គាត់ ឬការផ្ដល់-សក្ខីកម្ម[១០០]។

---

[៩៧] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១០៣ ១៣០ និង ១៤៣។ របាយការណ៍មួយទំព័ររបស់វេជ្ជបណ្ឌិត ចក់ ធីតា នៃមន្ទីរពេទ្យ កាល់ម៉ែត ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ សន្និដ្ឋានថា កង្វល់របស់លោកស្រី អៀង ធីរិទ្ធ អំពីស្ថានភាពសុខភាពរបស់គាត់ "ពុំបង្ហាញឲ្យឃើញនូវរោគសញ្ញានៃភាពមិនប្រក្រតីនៃស្ថានភាពផ្លូវចិត្តរបស់គាត់ទេ" (ការពិនិត្យស្ថានភាពជំងឺចិត្តសាស្ត្រ ឯកសារ E17/1/2.4 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ("របាយការណ៍របស់ ចក់ ធីតា")។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៨៩ (ដែលបានពន្យល់ថា ការវាយតម្លៃផ្សេងគ្នាទាំងនេះគឺដោយសារថា "មានភាពខុសគ្នាគួរឲ្យកត់សម្គាល់ពាក់ព័ន្ធនឹងរបៀបដែលលោកស្រី អៀង ធីរិទ្ធ សម្ដែងឫកពាទៅកាន់ និងប្រាស្រ័យទាក់ទងមនុស្សដែលកំពុងសម្ភាសគាត់ និងយើងអាចមើលឃើញ [...] អំពីភាពប្រែប្រួលនៃស្ថានភាពរបស់គាត់")។

[៩៨] ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៩២។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១៤៣ (ដែលបានកត់សម្គាល់ថា លោកស្រីមានបញ្ហាក្នុងការប្រើកំណត់ត្រាជាលាយលក្ខណ៍អក្សរក្នុងពេលធ្វើសម្ភាសជាមួយលោកស្រី)។

[៩៩] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១៣៨។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៥៤។

[១០០] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៦២-៦៥ ៦៧។

## ៤.៤ របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា និងសក្ខីកម្ម

៤០. ទោះបីជាអង្គជំនុំជម្រះជឿជាក់លើរបាយការណ៍ និងសក្ខីកម្មដែលផ្តល់ឲ្យដោយអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់យ៉ាងណាក្តី ក៏អង្គជំនុំជម្រះពិចារណាឃើញថា ជាការត្រឹមត្រូវអង្គជំនុំជម្រះត្រូវតែស្វះស្វែងរកការវាយតម្លៃបន្ថែមទៀត ពីអ្នកជំនាញវេជ្ជសាស្ត្រដែលមានឯកទេសក្នុងវិស័យដែលពាក់ព័ន្ធ។ អ្នកជំនាញផ្នែកវិកលវិទ្យា ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ បានពិនិត្យលោកស្រី អៀង ធីរិទ្ធ នៅថ្ងៃទី ១២ និង ១៣ ខែ កញ្ញា ឆ្នាំ ២០១១[១០១]។

៤១. បន្ទាប់ពីវាយតម្លៃជនជាប់ចោទរួចមក អ្នកជំនាញផ្នែកវិកលវិទ្យាក៏បានសន្និដ្ឋានផងដែរថា លោកស្រី អៀង ធីរិទ្ធ មានរោគសញ្ញានៃជំងឺវង្វេងវង្វាន់ស្មារតី រកឃើញតាមរយៈការវិនិច្ឆ័យរោគតាមបែបវេជ្ជសាស្ត្រ។ អ្នកជំនាញរកឃើញថា ការចងចាំរបស់គាត់មានការចុះខ្សោយកម្រិតមធ្យម និងសមត្ថភាពនៃសតិបញ្ញាដទៃទៀតមានភាពចុះខ្សោយពីកម្រិតស្រាលទៅកម្រិតមធ្យម[១០២]។ នៅពេលពិនិត្យលោកស្រី អៀង ធីរិទ្ធ អ្នកជំនាញបានប្រើប្រាស់តេស្តបីប្រភេទ៖ (១) តេស្តពិនិត្យស្ថានភាពផ្លូវចិត្ត ដើម្បីវាយតម្លៃអារម្មណ៍ ការនិយាយស្តី និងរោគសញ្ញាផ្លូវចិត្ត (២) តេស្តសតិបញ្ញាជាក់លាក់ខ្លះ រួមទាំងតេស្ត MMSE និង (៣) តេស្តដទៃទៀត ដើម្បីវាស់ស្ទង់មុខងារប្រតិបត្តិការវិនិច្ឆ័យ និងការរកហេតុផល[១០៣]។ មានតេស្តមួយចំនួនទៀតត្រូវបានយកមកអនុវត្តបន្ថែមទៅលើតេស្តប្រភេទទីបីនេះ ដើម្បីវាយតម្លៃការចងចាំរយៈពេលខ្លី និងវែងរបស់ជនជាប់-ចោទ[១០៤]។

៤២. បន្ទាប់ពីធ្វើតេស្តទាំងនេះ និងការពិនិត្យប្រវត្តិនៃការវិនិច្ឆ័យរោគរបស់លោកស្រីរួចមក អ្នកជំនាញផ្នែកវិកលវិទ្យាបានរកឃើញថា ជនជាប់ចោទមានបញ្ហាខ្សោយផ្នែកការចងចាំ ដោយគាត់មិន

---

[១០១] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៥។

[១០២] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២៧ (ដោយពិពណ៌នាថា ការចុះខ្សោយរបស់ជនជាប់ចោទបណ្តាលឲ្យគាត់មាន"បញ្ហាលំបាកខ្លាំងក្នុងការរស់នៅដោយឯករាជ្យខ្លួនឯង")។

[១០៣] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៩០-៩៣។

[១០៤] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៩៣។

អាចនឹកឃើញនូវព្រឹត្តិការណ៍ជាច្រើនក្នុងខ្សែជីវិតរបស់គាត់[១០៥]។ ឧទាហរណ៍ គាត់មិនចាំថាតើគាត់មានកូនប៉ុន្មាននាក់ ថាតើកូនៗទាំងនោះរស់នៅឯណា ឬថាតើពួកគេធ្វើអ្វីនោះទេ ទោះបីគាត់ពិតជាចាំថា គាត់មានកូនស្រីមួយនាក់ក៏ដោយ[១០៦]។ មិនតែប៉ុណ្ណោះ គាត់មិនចាំឈ្មោះម្តាយគាត់ ឬបងប្អូនបង្កើតរបស់គាត់នោះទេ[១០៧]។ នៅពេលអ្នកជំនាញផ្នែកវិកលវិទ្យាចូលទៅជួបគាត់នៅថ្ងៃបន្ទាប់ លោកស្រី អៀង ធីរិទ្ធ ចាំមុខមន្ត្រីបកប្រែភាសាម្នាក់ ប៉ុន្តែលោកស្រីមិនចាំឈ្មោះរបស់អ្នកជំនាញ ឬតួនាទីរបស់ពួកគាត់នោះទេ[១០៨]។ ជាផ្នែកមួយនៃតេស្ត MMSE អ្នកជំនាញបានប្រាប់ឲ្យជនជាប់ចោទចាំឈ្មោះវត្ថុបីខុសៗគ្នា ប៉ុន្តែគាត់មិនចាំវត្ថុទាំងនោះទេ[១០៩]។ អ្នកជំនាញបានសន្និដ្ឋានថា ការចងចាំរយៈវែងរបស់ជនជាប់ចោទត្រូវបានចុះខ្សោយ ទោះបីនៅមានការចងចាំខ្លះៗយ៉ាងណាក្តី និងថា ការចងចាំរយៈពេលខ្លីរបស់គាត់ក៏មានភាពចុះអន់ខ្សោយផងដែរ[១១០]។ ពួកគាត់បានកត់សម្គាល់បន្ថែមទៀតថា ការចងចាំរបស់ជនជាប់ចោទមើលទៅដូចជាមានសភាពកាន់តែចុះអន់ខ្សោយជាងមុន ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ[១១១]។

៤៣. ប៉ុន្តែអ្នកជំនាញបានកត់សម្គាល់ឃើញថា លោកស្រី អៀង ធីរិទ្ធ ធ្វើបានល្អក្នុងផ្នែកមួយចំនួននៅថ្ងៃពិនិត្យទីពីរ ជាងនៅថ្ងៃទីមួយ[១១២]។ ឧទាហរណ៍ គាត់អាចប្រកបពាក្យក្នុងភាសាអង់គ្លេសបាននៅថ្ងៃទីពីរ ប៉ុន្តែនៅថ្ងៃទីមួយ គាត់ប្រកបពាក្យនេះមិនបាននោះទេ និងគាត់ចាំឈ្មោះសាលាដែលគាត់

---

[១០៥] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៩។
[១០៦] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៩ ១៨។
[១០៧] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣១។
[១០៨] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២៤។
[១០៩] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៩១។
[១១០] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២៤ ៣០។
[១១១] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ១៧ ១៩ (ដែលបានកត់សម្គាល់ថា "វេជ្ជបណ្ឌិត ចំរើន នៃមន្ទីរពេទ្យកាល់ម៉ែត... យល់ឃើញថា ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ មានសភាពចុះអន់ខ្សោយជាងមុន និងគាត់មានប្រសាសន៍ថា លោកស្រីចាប់ផ្តើមត្អូញថាលោកស្រីភ្លេចភ្លាំង" និងថា លោក អៀង សារី បាននិយាយថាគាត់កត់សម្គាល់ឃើញ"ការប្រែប្រួលខ្លាំង គាត់ [អៀង ធីរិទ្ធ] ចេះតែភ្លេច")។
[១១២] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៩០-៩១។

រៀនតែនៅថ្ងៃទីពីរប៉ុណ្ណោះ[១១៣]។ ទោះបីជាអ្នកជំនាញកត់សម្គាល់ឃើញថា របាយការណ៍មួយពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ពាក់ព័ន្ធនឹងមុខងារសតិបញ្ញារបស់ជនជាប់ចោទ មានលក្ខណៈសុទិដ្ឋិនិយមជាងនេះយ៉ាងណាក៏ដោយ ក៏ពួកគាត់យល់ឃើញថា របាយការណ៍នេះពុំមានផ្តល់សេចក្តីលម្អិតអំពីរបៀបធ្វើតេស្តរកមើលមុខងារសតិបញ្ញានោះទេ។ ហេតុដូច្នេះ អ្នកជំនាញសន្និដ្ឋានថា ពួកគាត់មានការលំបាកក្នុងការវាយតម្លៃអំពីភាពគួរឱ្យជឿទុកចិត្តបាននៃរបាយការណ៍នេះណាស់[១១៤]។

៤៤. អ្នកជំនាញផ្នែកវិកលវិទ្យា បានរកឃើញថា លទ្ធផលស្កែនខួរក្បាលមានភាពស៊ីសង្វាក់គ្នាទៅនឹងជំងឺវង្វេងវង្វាន់ស្មារតី ឬការប្រែប្រួលពាក់ព័ន្ធទៅនឹងវ័យ[១១៥]។ បន្ទាប់ពីបានពិគ្រោះជាមួយវេជ្ជបណ្ឌិតផ្នែកកាំរស្មី អ្នកជំនាញផ្នែកវិកលវិទ្យាយល់ឃើញថា លទ្ធផលស្កែនខួរក្បាលពីឆ្នាំ ២០០៧ ឆ្នាំ ២០០៩ និង ឆ្នាំ ២០១១ បង្ហាញឱ្យឃើញនូវការរួញស្វិតនៃខួរក្បាលជាលក្ខណៈទូទៅ និងវិវឌ្ឍទៅមុខមួយ ដែលបញ្ជាក់អំពីរោគសញ្ញានៃជំងឺវង្វេងវង្វាន់ស្មារតី[១១៦]។

៤៥. អ្នកជំនាញផ្នែកវិកលវិទ្យាយល់ស្របជាមួយសាស្ត្រាចារ្យ CAMPBELL ថា រោគសញ្ញាដែលទំនងជាកើតមានគឺជំងឺ Alzheimer[១១៧]។ ពួកគាត់សន្មតដាក់ពិន្ទុឱ្យលោកស្រី អៀង ធីរិទ្ធ ត្រឹមដំណាក់កាលទី ៥ ក្នុងតំណាក់កាលទាំង ៧ ("ដោយតំណាក់កាលទី ៥ នេះគឺ៖ តំណាក់កាលចាប់ផ្តើមមានជំងឺវង្វេងវង្វាន់ស្មារតី៖ ការចុះខ្សោយសតិបញ្ញាកម្រិតធ្ងន់មធ្យម") និងបានកត់សម្គាល់ឃើញថា ទៅថ្ងៃមុខ ជំងឺនេះនឹងឈានទៅធ្វើឱ្យការចងចាំ និងមុខងារសតិបញ្ញារបស់គាត់

---

[១១៣] ប្រតិចារិក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៩០-៩១ ១០១។

[១១៤] ប្រតិចារិក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៩៩ (យោងទៅរករបាយការណ៍របស់វេជ្ជបណ្ឌិត ចក់ ធីតា)។

[១១៥] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៥។

[១១៦] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៥។

[១១៧] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៦ (បានវាយតម្លៃផងដែរអំពីជំងឺវង្វេងវង្វាន់ស្មារតីដោយសារការខូចសរសៃឈាមក្នុងខួរក្បាល ដែលអាចជារោគសញ្ញាមួយទៀតនៃជំងឺនេះ ប៉ុន្តែកត់សម្គាល់ថា"ការធ្វើរោគវិនិច្ឆ័យ បង្ហាញឱ្យឃើញនូវការចុះខ្សោយខ្លាំងជាលំដាប់" និងមានភាពស៊ីសង្វាក់គ្នានៃជំងឺ Alzheimer ជាងជំងឺវង្វេងវង្វាន់ស្មារតីដោយសារការខូចសរសៃឈាមក្នុងខួរក្បាល)។ អ្នកជំនាញផ្នែកវិកលវិទ្យា បានគូសបញ្ជាក់បន្ថែមទៀតថា ជួនកាលរោគសញ្ញាទីពីរនេះកើតឡើងក្នុងពេលដំណាលគ្នានឹងជំងឺAlzheimer's (ប្រតិចារិក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៣៦)។

ចុះខ្សោយជាលំដាប់[១១៨]។ អ្នកជំនាញបានបញ្ជាក់ថា ទៅថ្ងៃមុខសមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ នឹងប្រែប្រួល ហើយការប្រែប្រួលនេះនឹងកើតមានដូចការរំពឹងទុក ដោយសារតែការវិភាគឃើញរោគសញ្ញាវង្វេងវង្វាន់ស្មារតី[១១៩]។

៤៦. ចំពោះផលប៉ះពាល់ដែលអាចមានពីការបន្ថយឱសថសម្រួលបញ្ហាផ្លូវចិត្តរបស់ជនជាប់ចោទ អ្នកជំនាញបានកត់សម្គាល់ថា ការបន្ថយនេះពុំមានសញ្ញាណណាមួយដែលបញ្ជាក់ថា ការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ មានភាពប្រសើរឡើងវិញនោះទេ[១២០]។ បើការបន្ថយឱសថទាំងនេះពិតជាអាចផ្តល់ផលប្រយោជន៍អ្វីមួយមែននោះ គេទំនងជាអាចមើលឃើញផលនោះហើយនៅពេលនេះ។ ដូច្នេះ ទោះបីជាត្រូវកាត់បន្ថយឱសថបន្ថែមទៀតយ៉ាងក៏ដោយ ក៏ការបន្ថយនេះទំនងជាមិនធ្វើឱ្យមានការប្រសើរឡើងគួរឱ្យកត់សម្គាល់អ្វីនោះដែរ[១២១]។ លើសពីនេះទៅទៀត ជំងឺ Alzheimer មិនមែនជាទម្រង់នៃជំងឺវង្វេងវង្វាន់ស្មារតី ដែលអាចត្រឡប់មកវកសភាពដើម ឬអាចព្យាបាលបាននោះទេ[១២២]។ លទ្ធភាពនៃការព្យាបាលដោយប្រើឱសថចំពោះជំងឺ Alzheimer ដូចដែលសាស្ត្រាចារ្យ CAMPBELL លើកឡើងនោះគឺគ្រាន់តែអាចធ្វើឱ្យប្រសើរឡើងបន្តិចបន្តួចប៉ុណ្ណោះ និងភាពប្រសើរឡើងនេះផ្តល់ផលបានតែលើមនុស្សមួយចំនួនតូចដែលបានប្រើវាប៉ុណ្ណោះ។ ជាងនេះទៅទៀត គេមិនដឹងច្បាស់ថា ឱសថនេះមាននៅប្រទេសកម្ពុជា ឬគេអាចត្រួតពិនិត្យការប្រើប្រាស់វានៅទីនេះបានដែរ ឬយ៉ាងណានោះទេ[១២៣]។

៤៧. ទោះបីជាយ៉ាងនេះក្តី អ្នកជំនាញផ្នែកវិកលវិទ្យារកឃើញថា លោកស្រី អៀង ធីរិទ្ធ នៅស្គាល់បរិយាកាសជុំវិញខ្លួនគាត់នៅឡើយ និងគាត់អាចបង្ហាញសមត្ថភាពក្នុងការគ្រប់គ្រងការផ្តល់អារម្មណ៍ និងចូលរួមក្នុងកិច្ចសម្ភាសន៍បានខ្លះ និងគាត់អាចឆ្លើយតបទៅនឹងសំណួរបានក្នុងរយៈពេល

---

[១១៨] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៦។

[១១៩] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៥១។

[១២០] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ១៧។

[១២១] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៧។

[១២២] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ១២៩។

[១២៣] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៧។

យូរគួរសម[១២៤]។ អ្នកជំនាញយល់ឃើញថា សុខភាពផ្លូវកាយរបស់គាត់ពុំមានបញ្ហាអ្វីដែលប៉ះពាល់ដល់សម្បទាក្នុងការចូលរួមសវនាការរបស់គាត់ទេ[១២៥]។

៤៨. ពេលឆ្លើយទៅនឹងសំណួរ ដែលពាក់ព័ន្ធនឹងលទ្ធភាពដែលជនជាប់ចោទអាចប៉ុនប៉ងធ្វើពុតជាមានបញ្ហាអសមត្ថភាពផ្នែកពុទ្ធិ អ្នកជំនាញផ្នែកវិកលវិទ្យាបានពន្យល់ថា តេស្តបទដ្ឋានដែលយកមកប្រើក្នុងការវាយតម្លៃសមត្ថភាព និងវិធីសាស្ត្រដែលអ្នកជំនាញផ្នែកវិកលវិទ្យាបានប្រើក្នុងការវាយតម្លៃជនជាប់ចោទ ត្រូវបានរៀបចំឡើងដើម្បីរកឱ្យឃើញនូវលទ្ធភាពធ្វើពុតនេះ[១២៦]។ ដូច្នេះបើតាមទស្សនៈរបស់អ្នកជំនាញផ្នែកវិកលវិទ្យា ការធ្វើពុតទំនងជាមិនមានទេ[១២៧]។

៤៩. ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលត្រូវបានកំណត់ក្នុងរឿងក្តី *Strugar* អ្នកជំនាញផ្នែកវិកលវិទ្យាសន្និដ្ឋានថា ជនជាប់ចោទពិតជាមានសមត្ថភាពក្នុងការឆ្លើយតបទៅនឹងបទចោទ យល់ដឹងអំពីបទចោទលើរូបគាត់ យល់ដឹងអំពីសេចក្តីលម្អិតនៃភស្តុតាង និងផ្តល់សក្ខីកម្ម[១២៨]។ ទោះបីជាពីដំបូងលោកស្រី អៀង ធីរិទ្ធ ប្រាប់ថា គ្មាននរណាចោទប្រកាន់គាត់ពីបទអ្វីនោះក៏ដោយ ក៏ក្រោយមកគាត់យល់ច្បាស់អំពីភាពខុសគ្នារវាងមានពិរុទ្ធ និងគ្មានពិរុទ្ធ និងអះអាងថា គាត់ "មិនដែលសម្លាប់នរណាម្នាក់ទេ"[១២៩]។ ក្រោយមកទៀត គាត់និយាយថា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិមានលក្ខណៈ "ធ្ងន់ធ្ងរណាស់" ដោយមានន័យថា អស់ប្រជាជនមួយប្រទេស និងថាពាក្យប្រល័យ

---

[១២៤] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២៧(iii) ២៩ ៣២។

[១២៥] ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៤០ ៦២។

[១២៦] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៤។ ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ២៩ (ដែលបានពន្យល់ជាឧទាហរណ៍ ថាពួកគាត់បានប្រើប្រាស់ព័ត៌មានពីអ្នកផ្តល់ព័ត៌មានពីមុខៗ ដូចជាពីវេជ្ជបណ្ឌិតមុនៗដែលបានព្យាបាលអ្នកជំងឺ បុគ្គលិកថែទាំអ្នកជំងឺ និងបុគ្គលិកមន្ទីរឃុំឃាំង ដើម្បីយកមកផ្ទៀងផ្ទាត់បញ្ជាក់អំពីការវិភាគរកឃើញរោគសញ្ញាដែលអ្នកជំនាញរកឃើញ)។

[១២៧] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៦ (ដោយបានកត់សម្គាល់ថា ប្រសិនបើជនជាប់ចោទមានចេតនាចង់បោកបញ្ឆោតអ្នកជំនាញផ្នែកវិកលវិទ្យាអំពីភាពចុះខ្សោយសតិបញ្ញារបស់គាត់មែន នោះគាត់ទំនងជាមិនអាចធ្វើទៅរួចទេ ដ្បិតក្នុងរយៈពេលបីថ្ងៃខុសៗគ្នានោះ តេស្តត្រូវបានយកមកធ្វើដើម្បីរកមើលក្រែងគាត់ធ្វើត្រូវបានច្រើនជាងមុន)។

[១២៨] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤១ ៤២ ៤៤ ៤៧។

[១២៩] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤១។

ពូជសាសន៍គឺសំដៅលើ "ប្រជាជនទាំងមូល"[១៣០]។ គាត់បានស្តែងឱ្យឃើញអំពីសមត្ថភាពខ្លះក្នុងការយល់ដឹងអំពីបច្ច័យនៃកិច្ចដំណើរការនីតិវិធី៖ ការបង្ហាញខ្លួន ឧទាហរណ៍ គាត់បានបង្ហាញអំពីការយល់ដឹងត្រង់ចំណុចមួយក្នុងពេលវាយតម្លៃថា ប្រសិនបើគេរកឃើញថា គាត់គ្មានសម្បទាដើម្បីចូលរួមក្នុងសវនាការបាន គេមិនអាចកាត់ទោសគាត់បានទេ[១៣១]។

៥០. ទោះជាយ៉ាងនេះក្តី សមត្ថភាពរបស់ជនជាប់ចោទក្នុងការយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធី អ្នកជំនាញផ្នែកវិកលវិទ្យាសន្និដ្ឋានថា៖

> ការអន់ថយខាងសតិបញ្ញារបស់ លោកស្រី អៀង ធីរិទ្ធ នឹងធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពក្នុងការយល់ដឹងអំពីអ្វីដែលបាននិយាយនៅក្នុងតុលាការ សមត្ថភាពក្នុងការធ្វើយុត្តិកម្ម និងថ្លឹងថ្លែងពីព័ត៌មាន និងសមត្ថភាពក្នុងការផ្តល់ជាមតិយោបល់ឱ្យបានច្បាស់លាស់លើព័ត៌មាននោះ។ ជាពិសេស យើងខ្ញុំយល់ឃើញថា គាត់នឹងមិនអាចចងចាំនូវព័ត៌មានដែលមាននៅក្នុងសេចក្តីថ្លែង ឬ សារណានានានៅក្នុងតុលាការ ឱ្យបានយូរដើម្បីឱ្យគាត់អាចផ្តល់ជាមតិយោបល់តបទៅលើសារណាទាំងនោះ ឱ្យបានច្បាស់លាស់ឡើយ។ម្យ៉ាងវិញទៀត យើងខ្ញុំយល់ឃើញថា ការកត់ត្រា ចំណាំរបស់គាត់ នឹងមិនអាចជួយបង្កើនសមត្ថភាពរបស់គាត់ឱ្យដល់កម្រិតមួយដែលមានលក្ខណៈគ្រប់គ្រាន់ សម្រាប់គោលបំណងនៃការយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីបានឡើយ[១៣២]។

៥១. ជាងនេះទៅទៀត អ្នកជំនាញផ្នែកវិកលវិទ្យា យល់ឃើញថា ជនជាប់ចោទមិនអាចណែនាំដល់មេធាវីរបស់គាត់បានទេ៖

> យើងខ្ញុំយល់ឃើញថា លោកស្រី អៀង ធីរិទ្ធ នឹងមានការលំបាកខ្លាំងនៅក្នុងការជួយដល់ការត្រៀមរៀបចំការការពារក្តីរបស់គាត់ ដោយសារតែការចុះអន់ថយនៃការចងចាំរបស់គាត់មិនថា ពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់នៅក្នុងអំឡុងពេលនៃការប្រព្រឹត្តិបទល្មើសដែលត្រូវបានចោទប្រកាន់នោះទេ វាថែមទាំងពាក់ព័ន្ធទៅនឹងការចងចាំរបស់គាត់ទៅលើបរិបទទូលំ-

---

[១៣០] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤២។

[១៣១] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤៦។

[១៣២] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤៣។

ទូលាយជាងនេះ អំពីជីវិតរបស់គាត់នាពេលនោះផងដែរ[១៣៣]។

## ៤.៥ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសមត្ថភាពដើម្បីចូលរួមក្នុងសវនាការរបស់លោកស្រី អៀង ធីរិទ្ធ

៥២. អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ឃើញថា ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ អ្នកជំនាញគ្រប់រូបសុទ្ធតែបានវិភាគស៊ីសង្វាក់គ្នា ដោយរកឃើញនូវរោគសញ្ញានៃជំងឺវង្វេងវង្វាន់ស្មារតីដែលទំនងជាបណ្ដាលមកពីជំងឺ Alzheimer[១៣៤]។ អ្នកជំនាញទាំងអស់សុទ្ធតែបានយល់ស្របគ្នាថាជនជាប់ចោទមានជំងឺចុះខ្សោយសតិបញ្ញាគួរឲ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹងការចងចាំរយៈពេលខ្លី និងការចងចាំរយៈពេលវែងរបស់គាត់។ កំណត់ហេតុវេជ្ជសាស្ត្របង្ហាញថា លោកស្រី អៀង ធីរិទ្ធ មិនអាចចងចាំព័ត៌មានផ្ទាល់ខ្លួនសាមញ្ញៗ ដូចជាព័ត៌មានលម្អិតស្ដីពីក្រុមគ្រួសារផ្ទាល់របស់គាត់[១៣៥]។ អ្នកជំនាញបានពន្យល់ថា ពិន្ទុ ២៣/៣០ ឬទាបជាងនេះនៅលើតេស្ត MMSE (តេស្តដើម្បីរកមើលសមត្ថភាពសតិបញ្ញា) គឺជាសញ្ញាណបញ្ជាក់អំពីភាពចុះខ្សោយ និងថា លោកស្រី អៀង ធីរិទ្ធ ធ្វើបានពិន្ទុ ១៤/៣០ និង ១៥/៣០ និង ១៨/៣០ នៅលើតេស្តនេះក្នុងពេលនៃការវាយតម្លៃជាប់ៗគ្នាដែលត្រូវបានធ្វើឡើងដោយអ្នកជំនាញ នៅរវាងខែ មិថុនា និងខែ តុលា ឆ្នាំ ២០១១[១៣៦]។ ទោះបីជាអ្នកជំនាញទទួលស្គាល់ថា លោកស្រី អៀង ធីរិទ្ធ អាចធ្វើពុតជាមានជំងឺ

---

[១៣៣] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤៥។

[១៣៤] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២៧ និង ២៧(v)។ របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៣៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៣៥-៣៦ ៣៨ និង របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៦ (ដោយរកឃើញថា លទ្ធផលនៃការស្កេនខួរក្បាលលោកស្រី អៀង ធីរិទ្ធ មានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងការវិភាគរោគសញ្ញានេះ និងបានបង្ហាញអំពីការរួញស្វិតខួរក្បាលដែលចេះតែវិវឌ្ឍជាលំដាប់ ពី ឆ្នាំ ២០០៧ ដល់ ឆ្នាំ ២០១១)។

[១៣៥] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៩ ១៨ ៣១។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៣២។ ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១១៣-១១៤។ របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១៩ ២០។

[១៣៦] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២១។ របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ១១ (ដោយបានកត់សម្គាល់ឃើញថា វេជ្ជបណ្ឌិតខាងធ្វើរោគវិនិច្ឆ័យនៃមន្ទីរពេទ្យកាល់ម៉ែត បានកត់ត្រានូវពិន្ទុ ២៣-២៤/៣០ កាលពីឆ្នាំមុន ប៉ុន្តែអ្នកជំនាញមិនអាចផ្ទៀងផ្ទាត់លទ្ធផលនេះបាន)។

ចុះខ្សោយសតិបញ្ញាយ៉ាងក៏ដោយ បន្ទាប់ពីពិនិត្យមើលលទ្ធផលនៃការរកឃើញពីភាពអសមត្ថភាពរួចមក អ្នកជំនាញទាំងអស់សុទ្ធតែយល់ឃើញថា លោកស្រី អៀង ធីរិទ្ធ ទំនងជាមិនអាចធ្វើពុតជាមានជំងឺវង្វេងវង្វាន់ស្មារតីនេះបាននោះទេ[១៣៧]។

៩៣. ចុងបញ្ចប់ អ្នកជំនាញទាំងអស់ សុទ្ធតែយល់ស្របគ្នាថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺមួយដែលចេះតែវិវឌ្ឍទៅមុខ និងធ្លាក់ដុនដាបជាលំដាប់[១៣៨]។ ដូច្នេះ ជាការច្បាស់ណាស់ដែលថាការចងចាំរយៈពេលខ្លី និងការចងចាំរយៈពេលវែងរបស់លោកស្រី អៀង ធីរិទ្ធ ពេលនេះមានកម្រិតរួចទៅហើយ និងស្ថានភាពរបស់គាត់នឹងបន្តចុះអន់ខ្សោយជាលំដាប់ទៅថ្ងៃខាងមុខ[១៣៩]។ ទោះបីជាសាស្ត្រាចារ្យ CAMPBELL ផ្តល់អនុសាសន៍ឱ្យសាកល្បងប្រើឱសថមួយទៀតដើម្បីព្យាបាលជំងឺ Alzheimer យ៉ាងណាក្តី ក៏អ្នកជំនាញទាំងអស់សុទ្ធតែយល់ស្របគ្នាថា លទ្ធភាពដែលឱសថនេះអាចធ្វើឱ្យស្ថានភាពរបស់លោកស្រីមានភាពប្រសើរឡើងវិញ គឺមានតិចតួចណាស់ និងពួកគាត់បានយល់ឃើញថា ការត្រួតពិនិត្យ និងតាមដានការប្រើឱសថនេះអាចមានការលំបាកក្នុងបរិបទកម្ពុជា[១៤០]។ ឱសថសម្រួលស្ថានភាពផ្លូវចិត្តដែលលោកស្រី អៀង ធីរិទ្ធ បានប្រើប្រាស់ និងដែលត្រូវបានណែនាំឱ្យកាត់បន្ថយ ត្រូវបានកាត់បន្ថយជាច្រើនរួចមកហើយ ប៉ុន្តែជាលទ្ធផលការចងចាំរបស់គាត់ពុំមានភាពល្អប្រសើរអ្វីនោះទេ[១៤១]។

---

[១៣៧] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៥។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១៣៥។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៥៥។

[១៣៨] របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៧។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៥។ របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៦។

[១៣៩] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១១៦។ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៩ ១១

[១៤០] របាយការណ៍វាយតម្លៃបន្ថែមរបស់គ្រូពេទ្យព្យាបាលមនុស្សចាស់ កថាខណ្ឌ ៨(ii)។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១៤០។ របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៧។ ប្រិតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៧៦។

[១៤១] របាយការណ៍វាយតម្លៃបន្ថែមរបស់គ្រូពេទ្យព្យាបាលមនុស្សចាស់ កថាខណ្ឌ ៦។ របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ១៧ ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ១១០ និង ប្រិតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១១៩ ១២៤ និង ១៣៨ (ដោយបានកត់សម្គាល់ថា ជនជាប់ចោទបន្តបន្ថយកម្រិតឱសថសម្រួលស្ថានភាពផ្លូវចិត្តមួយប្រភេទ ការបន្ថយឱសថនេះពុំមានផ្តល់ផលល្អប្រសើរណាមួយគួរឱ្យកត់សម្គាល់នោះទេ និងសន្និដ្ឋានថា ការបញ្ឈប់ឱសថនេះ

៥៤. បញ្ហានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ គឺថាតើកម្រិតនៃការចុះខ្សោយសតិបញ្ញាដូចដែលអ្នកជំនាញបានរកឃើញនោះ បើផ្ទៀងផ្ទាត់គ្នាជាមួយនឹងលក្ខណៈវិនិច្ឆ័យដូចមានក្នុងរឿងក្ដី *Strugar* អាចប៉ះពាល់ដល់លទ្ធភាពក្នុងការជំនុំជម្រះក្ដីបានដោយយុត្តិធម៌ដែរ ឬយ៉ាងដូចម្ដេច។ បន្ទាប់ពីវាយតម្លៃសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញពាក់ព័ន្ធនឹងកត្តាដែលទាក់ទិននឹងការវាយតម្លៃនេះ អង្គជំនុំជម្រះយល់ឃើញថា សមត្ថភាពជាច្រើនដែលមានលើកឡើងក្នុងរឿងក្ដី *Strugar* មានលក្ខណៈពាក់ព័ន្ធគ្នាទៅវិញទៅមក ឬត្រួតស៊ីគ្នា។

### *៤.៥.១ ការផ្ដល់សក្ខីកម្ម ការឆ្លើយតបទៅនឹងបទចោទ ការយល់ដឹងអំពីលក្ខណៈនៃបទចោទ និងភាពលម្អិតនៃភស្តុតាង*

៥៥. សាស្ត្រាចារ្យ CAMPBELL យល់ឃើញថា លោកស្រី អៀង ធីរិទ្ធ នឹងមានបញ្ហាលំបាកក្នុងការផ្ដល់សក្ខីកម្មដើម្បីការពារក្ដីរបស់គាត់ និងមើលទៅគាត់ដូចជាមិនយល់អំពីលក្ខណៈនៃបទចោទ និងផលវិបាកនៃកិច្ចដំណើរការនីតិវិធីទេ[១៤២]។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ មិនចាំ "សវនាការដំបូង" ក្នុងសំណុំរឿង ០០២ ទេ (គឺសវនាការបឋម ដែលប្រព្រឹត្តទៅនៅក្នុងខែ មិថុនា ឆ្នាំ ២០១១)។ គាត់អត់ចាំបទចោទ ប៉ុន្តែផ្ទុយទៅវិញ គាត់បែរជាគិតថា "គ្មានការចោទប្រកាន់អ្វីមួយមកលើរូបខ្ញុំទេ"[១៤៣]។ ទោះជាយ៉ាងនេះក្ដី លោកសាស្ត្រាចារ្យបានកត់សម្គាល់ឃើញថា សមត្ថភាពក្នុងការឆ្លើយតបសំណួររបស់លោកស្រី អៀង ធីរិទ្ធ មានភាពប្រែប្រួលគួរឱ្យកត់សម្គាល់ និងស្ថានភាពរបស់គាត់ទំនងជាផ្លាស់ប្ដូរទៅតាមពេលវេលា[១៤៤]។

៥៦. ផ្ទុយទៅវិញ អ្នកជំនាញផ្នែកវិកលវិទ្យាបានកត់សម្គាល់ឃើញថា នៅពេលប្រឈមមុខនឹងសំណួរជាក់លាក់ដូចជាសំណួរពាក់ព័ន្ធនឹងនិយមន័យនៃពាក្យមានពិរុទ្ធ ឬគ្មានពិរុទ្ធ លោកស្រី អៀង ធីរិទ្ធ

---

ទំនងជាមិនអាចជួយឱ្យមុខងារសតិបញ្ញារបស់គាត់ប្រសើរជាងមុននោះឡើយ)។

[១៤២] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៦៤-៦៥។

[១៤៣] របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ២២។

[១៤៤] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៨៩។ *សូមមើលផងដែរ* របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៥១ (ដែលបានកត់សម្គាល់ស្រដៀងគ្នាថាការប្រែប្រួលនៃសមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ គឺកើតមានឡើងដោយសារជំងឺវង្វេងវង្វាន់ស្មារតីរបស់គាត់)។

ទំនងជាបង្ហាញនូវកម្រិតយល់ដឹងខ្លះ[១៤៥]។ មានភស្តុតាងបង្ហាញថា លោកស្រីនៅមានការចងចាំរយៈពេលវែងខ្លះៗ និងអាចឆ្លើយតបទៅនឹងសំណួរបាន[១៤៦]។ ឧទាហរណ៍ គាត់អាចពន្យល់ជាពាក្យសម្រាយអំពីអត្ថន័យនៃពាក្យបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ និងបានប្រកែកថា គាត់ពុំមានពិរុទ្ធភាពចំពោះបទចោទទាំងនេះនោះទេ[១៤៧]។ អ្នកជំនាញផ្នែកវិកលវិទ្យា បានកត់សម្គាល់បន្ថែមទៀតថា លោកស្រី អៀង ធីរិទ្ធ នៅពេលមួយក្នុងពេលវាយតម្លៃទំនងជាបានបង្ហាញឲ្យឃើញថា គាត់មានការយល់ដឹងអំពីផលវិបាកនៃការដែលតុលាការរកឃើញថាគាត់គ្មានសម្បទាដើម្បីចូលរួមក្នុងសវនាការ[១៤៨]។ ដូច្នេះ អ្នកជំនាញផ្នែកវិកលវិទ្យា យល់ឃើញថា លោកស្រីមានការយល់ដឹងខ្លះថា គាត់ត្រូវបានគេចោទប្រកាន់ និងអំពីអ្វីដែលគេចោទប្រកាន់មកលើគាត់។ ជាលទ្ធផល ពួកគាត់បានសន្និដ្ឋានថា លោកស្រី អៀង ធីរិទ្ធ នៅមានសមត្ថភាពខ្លះក្នុងការឆ្លើយតបទៅនឹងបទចោទ យល់ដឹងអំពីបទចោទ និងភាពលម្អិតនៃភស្តុតាងប្រឆាំងមកលើរូបគាត់ និងផ្តល់សក្ខីកម្ម[១៤៩]។

៩៧. អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងអ្នកជំនាញផ្នែកវិកលវិទ្យាថា ជនជាប់ចោទ អៀង ធីរិទ្ធ អាចនៅមានសមត្ថភាពខ្លះក្នុងការឆ្លើយតបទៅនឹងបទចោទ យល់ដឹងអំពីបទចោទមកលើរូបគាត់ យល់ដឹងអំពីភាពលម្អិតនៃភស្តុតាង និងផ្តល់សក្ខីកម្ម។ ប៉ុន្តែ ការចុះខ្សោយការចងចាំរបស់ជនជាប់ចោទ ទំនងជានឹងប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការរំឭកឡើងវិញឲ្យបានត្រឹមត្រូវនូវព្រឹត្តិការណ៍ដែលបានកើតឡើងរវាងឆ្នាំ ១៩៧៥ និង ១៩៧៩។ បញ្ហានេះនឹងត្រូវថ្លឹងថ្លែងដោយអង្គជំនុំជម្រះ នៅពេលវាយតម្លៃភស្តុតាង និងភាពដែលអាចជឿជាក់បានរបស់គាត់ ប្រសិនបើជនជាប់ចោទត្រូវផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ[១៥០]។ មិនតែប៉ុណ្ណោះ ការចុះខ្សោយសតិបញ្ញា

---

[១៤៥] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤១។

[១៤៦] ប្រតិចារិក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៧៩។

[១៤៧] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤២។

[១៤៨] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៤៦-៤៧។

[១៤៩] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ២០, ៤១, ៤២, ៤៤, ៤៦-៤៧ (ដោយបានកត់សម្គាល់ឃើញថា ជនជាប់ចោទអាចស៊ូទ្រាំឆ្លើយសំណួរអស់រយៈពេលពីរម៉ោងបាន ដោយមើលទៅគាត់ដូចជាមិនមានការអស់កម្លាំងអ្វីទេ)។

[១៥០] សេចក្តីសម្រេចក្នុងរឿងក្តី *Strugar* កថាខណ្ឌ ៤៩ (ដោយបានកត់សម្គាល់ភស្តុតាងដែលថា មានភាពចុះខ្សោយខ្លះពាក់ព័ន្ធ

របស់លោកស្រី អៀង ធីរិទ្ធ អាចបណ្តាលឱ្យក្រុមមេធាវីរបស់គាត់ប្រឈមមុខនឹងបញ្ហាលំបាក ឬ ការពន្យារក្នុងការពន្យល់អំពីលក្ខណៈនៃបទចោទ និងភស្តុតាងប្រឆាំងលើរូបគាត់ ដែលប្រការនេះ អាចនាំឱ្យការជំនុំជម្រះក្តីពាក់ព័ន្ធដល់ជនជាប់ចោទទាំងអស់ក្នុងសំណុំរឿង ០០២ មានភាពយឺតយ៉ាវ។

***៤.៥.២ ការយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធី និងការណែនាំដល់មេធាវីការពារក្តី***

៥៨. កត្តាដែលសំខាន់បំផុតដូចដែលបានគូសបញ្ជាក់ដោយអ្នកជំនាញទាំងអស់ គឺពាក់ព័ន្ធទៅនឹងការចុះខ្សោយការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ និងផលប៉ះពាល់នៃការចុះខ្សោយក្នុងការយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធី និងសមត្ថភាពក្នុងការណែនាំដល់មេធាវីរបស់គាត់។ ដើម្បីអាចអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឱ្យមានប្រសិទ្ធិភាពបាន ជាការសំខាន់ណាស់ដែលជនជាប់ចោទត្រូវតែអាចតាមដានសក្ខីកម្មឱ្យបានគ្រប់គ្រាន់ ដើម្បីផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅដល់មេធាវីការពាក្តី សម្រាប់ត្រៀមរៀបចំការការពារក្តីរបស់គាត់។

៥៩. អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយអ្នកជំនាញថា ការបាត់បង់ការចងចាំរយៈពេលខ្លី និងរយៈពេលវែងរបស់លោកស្រី អៀង ធីរិទ្ធ ច្បាស់ជាធ្វើឱ្យជនជាប់ចោទរូបនេះមិនអាចយល់ដឹងអំពីការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីឱ្យបានគ្រប់គ្រាន់ ដើម្បីអាចឱ្យគាត់ណែនាំមេធាវីការពារក្តីរបស់គាត់ឱ្យបានគ្រប់ជ្រុងជ្រោយ និងចូលរួមក្នុងការពារក្តីរបស់គាត់ឱ្យមានប្រសិទ្ធិភាពបាននោះទេ។ ដោយសារតែ លោកស្រី អៀង ធីរិទ្ធ មិនអាចអនុវត្តសិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងប្រកបដោយអត្ថន័យទាំងអស់នេះហើយ និងដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិដែលមានចែងនៅក្នុងរឿងក្តី *Strugar* ទើបអង្គជំនុំជម្រះគ្មានជម្រើសអ្វីក្រៅពីប្រកាសថា លោកស្រីពុំមានសម្បទាក្នុងការចូលរួមសវនាការ។

**៤.៦ __បច្ច័យនៃភាពគ្មានសម្បទាក្នុងការចូលរួមសវនាការរបស់លោកស្រី អៀង ធីរិទ្ធ__**

៦០. ទោះបីជាអង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់នូវស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទយ៉ាងណាក្តី ក៏អង្គជំនុំជម្រះបានរកឃើញផងដែរថា លោកស្រី អៀង ធីរិទ្ធ ពុំមានសមត្ថភាពអនុវត្តសិទ្ធិរបស់គាត់ ដូចដែលត្រូវបានការពារនៅក្នុងក្របខ័ណ្ឌច្បាប់របស់

---

នឹងសមត្ថភាពរបស់ *Strugar* ក្នុងការផ្តល់សេចក្តីកម្ម ដោយសារតែបញ្ហាផ្នែកការចងចាំ និងការថ្លង់អារម្មណ៍ ប៉ុន្តែបានសន្និដ្ឋានថា បញ្ហានេះត្រូវយកពិចារណានៅពេលវាយតម្លៃលើទម្ងន់នៃភាពគួរឱ្យជឿជាក់បាននៃសក្ខីកម្មរបស់ជនជាប់ចោទ)។

អ.វ.ត.ក ដើម្បីការពារក្តីប្រកបដោយប្រសិទ្ធភាពបាននោះទេ។ ការជំនុំជម្រះក្តី និងការបន្តឃុំខ្លួនជនជាប់ចោទណាមួយ ដែលគ្មានសមត្ថភាពយល់ដឹងអំពីកិច្ចដំណើរការនីតិវិធីប្រឆាំងមកលើរូបគាត់ ឬដែលគ្មានសមត្ថភាពចូលរួមការពារក្តីរបស់គាត់ប្រកបដោយអត្ថន័យបាន គឺពិតជាមិនបម្រើដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ ហើយការធ្វើដូច្នេះក៏នឹងមិនស្របទៅតាមបទដ្ឋានអន្តរជាតិ ដែលអង្គជំនុំជម្រះនេះត្រូវគោរពតាម ដោយអនុលោមទៅតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង ដែលចែងអំពីការធានាសិទ្ធិជាសារវន្ត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវអនុវត្តនៅចំពោះមុខតុលាការកម្ពុជាទាំងអស់នោះដែរ[១៥១]។

៦១. ជាងនេះទៅទៀត តាមរយៈការវិភាគរោគសញ្ញា លោកស្រី អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមានជំងឺដែលចេះតែវិវឌ្ឍ និងចុះដុនដាបជាលំដាប់។ អង្គជំនុំជម្រះទទួលយកគំនិតស្របគ្នាជាឯកច្ឆន្ទរបស់អ្នកជំនាញទាំងអស់ ដែលលើកឡើងថា ស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ នឹងបន្តចុះដុនដាបទៅថ្ងៃខាងមុខក្នុងអំឡុងពេលនៃការប្រព្រឹត្តិទៅនៃការជំនុំជម្រះក្តីដែលទំនងជាស្មុគស្មាញ និងប្រើពេលយូរ។ ដូច្នេះ ការពន្យារកិច្ចដំណើរការនីតិវិធី គឺទំនងជាមិនផ្តល់ផលប៉ះពាល់អ្វីក្រៅពីការប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទដទៃទៀតនៅក្នុងសំណុំរឿង ០០២ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស ដែលការជំនុំជម្រះក្តីនោះត្រូវបានគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ នេះនោះទេ[១៥២]។ អាស្រ័យហេតុនេះ ដើម្បីប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះ

---

[១៥១] *សូមមើលផងដែរ* មាត្រា ១៣ នៃកិច្ចព្រមព្រៀង (ដោយយោងទៅរកមាត្រា ១៤ និង ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី និងមាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ *សូមមើលផងដែរ* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣) ដែលបានអនុម័តដោយសភាធម្មនុញ្ញ និងចុះហត្ថលេខាដោយប្រធាន នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ មាត្រា ៣១ និង ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤៩ និងមាត្រា ៣១៨។

[១៥២] *សូមមើល ព្រះរាជអាជ្ញា ទល់នឹង Strugar និង Kovačević* សេចក្តីសម្រេចលើពាក្យរបស់ព្រះរាជអាជ្ញាស្នើសុំបំបែកការជំនុំជម្រះក្តី និងបង្គាប់ឲ្យកំណត់កាលបរិច្ឆេទរៀបការកិច្ចប្រជុំរៀបចំសវនាការ និងចាប់ផ្តើមការជំនុំជម្រះក្តីលើ Pavle Strugar អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY សំណុំរឿងលេខ IT-01-42-PT ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ (សម្រេចបំបែកនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ដែលការពិនិត្យសុខភាពផ្នែកវេជ្ជសាស្ត្ររបស់ Kovačević ទំនងជាមិនអាចបំពេញចប់សព្វគ្រប់បាននៅក្នុងរយៈពេលសមស្របមួយ ដូច្នេះការជំនុំជម្រះក្តី Strugar នឹងត្រៀមជាស្រេចដើម្បីចាប់ផ្តើមប្រព្រឹត្តទៅ និងនៅពេលដែលការមិនបានបំបែកកិច្ចដំណើរការនីតិវិធី នាំឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយឆាប់

សាលាដំបូងសម្រេចបំបែកបទចោទប្រឆាំងលើជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២ ដោយអនុលោមទៅតាមវិធាន ៨៩ ស្ទួនពីរ និងផ្អាកកិច្ចដំណើរការនីតិវិធីលើរូបគាត់។ ដូច្នេះ យោងទៅលើការរកឃើញរបស់ខ្លួនអំពីភាពគ្មានសមត្ថភាពក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី និង ការបំបែកបទចោទទាំងអស់ប្រឆាំងលើជនជាប់ចោទ រូបនេះ ដោយអនុលោមទៅតាមវិធាន ៨៩ ស្ទួនពីរ និងការផ្អាកកិច្ចដំណើរការនីតិវិធីលើរូបគាត់ក្នុងសំណុំរឿង ០០២ នោះ អង្គជំនុំជម្រះ សាលាដំបូងពុំមានមូលដ្ឋានណាមួយដើម្បីបន្តឃុំខ្លួនជនជាប់ចោទតទៅទៀតបានទេ។

៦២. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ស្របគ្នាជាឯកច្ឆន្ទលើចំណុចទាំងអស់ខាងលើយ៉ាងណាក្តី ក៏អង្គជំនុំជម្រះរកការយល់ស្របគ្នាមិនបានពាក់ព័ន្ធនឹងចំណុច ថាតើគួរបង្គាប់ឲ្យលោកស្រី អៀង ធីរិទ្ធ ឲ្យទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬថាតើគួរដោះលែងគាត់ដោយគ្មានលក្ខខណ្ឌ។ ដូច្នេះ ពាក់ព័ន្ធនឹងបញ្ហានៃការដោះលែងនេះ អង្គជំនុំជម្រះមានយោបល់ពីរដាច់ដោយឡែកពីគ្នាដូច ខាងក្រោម។

## ៤.៧ <u>មតិយោបល់របស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម យូរ ឧត្តរា</u>

៦៣. ជាគោលការណ៍ យើងយល់ស្របជាមួយសម្អាងហេតុរបស់ចៅក្រមអន្តរជាតិជាពិសេសទៅលើ ការរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ យោងទៅលើស្ថានភាពបច្ចុប្បន្នរបស់ជនជាប់ចោទគឺ នាំឲ្យកិច្ចដំណើការជំនុំជម្រះមិនអាចធ្វើបាន ចំពោះជននេះឡើយ។ ផ្អែកលើគោលការណ៍នៃការជំនុំជម្រះក្តីព្រហ្មទណ្ឌ និងគោលការណ៍ មនុស្សធម៌ នៅពេលដែលជនជាប់ចោទម្នាក់ត្រូវបានរកឃើញថា គ្មានសម្បទាគ្រប់គ្រាន់ក្នុងការ ចូលរួមសវនាការទេនោះ ជនជាប់ចោទរូបនោះគឺស្ថិតនៅក្នុងស្ថានភាពមួយដែលមិនអាចការពារ ខ្លួនបានឡើយ[១៥៣]។ នេះគឺជាសិទ្ធិមូលដ្ឋានដែលជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយ យុត្តិធម៌ ដែលមានចែងនៅក្នុងមាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក។ អង្គជំនុំជម្រះ បានសន្និដ្ឋានថា លោកស្រី អៀង ធីរិទ្ធ មិនមានសមត្ថភាពពេញលេញក្នុងការជំនុំជម្រះ និងការអនុវត្តនូវសិទ្ធិ

---

របស់របស់ជនជាប់ចោទទីពីររូបនេះ)។

[១៥៣] សូមមើលរដ្ឋអាជ្ញារង ទល់នឹង Josep Nahak ករណី 01A/2004 ផ្នែកសម្អាងហេតុ និងការសម្រេចលើសម្បទារបស់ របស់ជនជាប់ចោទរូបនេះ ក្នុងការចូលរួមសវនាការ សេចក្តីសម្រេចចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ៤៨។

00753968



ទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់គាត់នោះទេ។ យើងយល់ស្របនឹងការសន្និដ្ឋានដែលថា ការដែលអង្គជំនុំជម្រះនៅតែបន្តកិច្ចដំណើការនីតិវិធីទៅលើជនជាប់ចោទ អៀង ធីរិទ្ធ ជាបន្តទៀត នោះ នឹងមិនបម្រើឱ្យផលប្រយោជន៍យុត្តិធម៌ឡើយ។

៦៤. ទោះបីជាយ៉ាងនេះក្តី យើងមិនឈានទៅដល់ការយល់ស្របគ្នាជាមួយសហសេវិកអន្តរជាតិចំពោះបច្ច័យដែលកើតចេញពីការសន្និដ្ឋានខាងលើនេះបានទេ។ អង្គជំនុំជម្រះយល់ឃើញថា ជាប្រយោជន៍យុត្តិធម៌ ដែលត្រូវបំបែកបទចោទប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ដោយអនុលោមទៅតាមវិធាន ៨៩ ស្ទួនពីរ និងផ្អាកកិច្ចដំណើរការនីតិវិធីលើរូបគាត់ក្នុងសំណុំរឿង ០០២[១៥៤]។ ជាថ្មីម្តងទៀត យើងយល់ស្របនឹងការយល់ឃើញបែបនេះ ដូចនឹង សហសេវិកអន្តរជាតិដែរ និង កត់សម្គាល់ថា កិច្ចដំណើការនីតិវិធីចំពោះជនជាប់ចោទគ្រាន់តែផ្អាកមិនមែនបញ្ចប់នោះទេ។ មានន័យថា អនុលោមតាមមាត្រា ៧ និងមាត្រា ៨ នៃក្រមនីតិវិធី ព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បទចោទទាំងអស់ប្រឆាំងនឹង អៀង ធីរិទ្ធ គឺមិនរលត់ឡើយ។ ក៏ប៉ុន្តែ យើងមិនអាចឈានទៅដល់ការឯកភាពគ្នាមួយពាក់ព័ន្ធនឹងការដោះ លែងជនជាប់ចោទ អៀង ធីរិទ្ធ ជាបន្ទាន់ចេញពីមន្ទីរឃុំឃាំង អ.វ.ត.ក[១៥៥]។ យើងយល់ថា ជនជាប់ចោទមិនគួរត្រូវបានដោះលែងភ្លាមដូច្នេះនាពេលនេះនោះទេ។ ផ្ទុយទៅវិញ យើងយល់ ឃើញថា អង្គជំនុំជម្រះគួរពិនិត្យមើលជាបឋមទៅលើលទ្ធភាពនានាថា តើស្ថានភាពរបស់ លោកស្រី អៀង ធីរិទ្ធ អាចប្រសើរឡើងវិញនាពេលខាងមុខដែរ ឬយ៉ាងណា ដែលជួនកាលអាចឱ្យគាត់ចូលរួមក្នុងការជំនុំជម្រះក្តីបាន។ ក្នុងន័យនេះ យើងកត់សម្គាល់ទៅលើរបាយការណ៍របស់អ្នកជំនាញ ដែលបានសរសេរនៅត្រង់ កថាខណ្ឌ ៣៨ ថា៖

យើងខ្ញុំក៏ត្រូវបានស្នើឱ្យផ្តល់ជាយោបល់ថាតើមានការព្យាបាល ឬវិធានការដទៃផ្សេងទៀតដែលអាចផ្តល់ផលប្រយោជន៍ដល់ស្ថានភាពស្មារតី និងមុខងារសតិបញ្ញារបស់លោកស្រី អៀង ធីរិទ្ធ ដែរ ឬទេ។ ខាងក្រោមនេះអាចមានប្រយោជន៍បាន៖ (ក) ការរក្សាចំនួនបុគ្គលិក និងបុគ្គលិកដដែល (ខ) ការរក្សាឱ្យមានបរិស្ថានដដែល (គ) ការបទបែនដើម្បីសម្របទៅនឹងលទ្ធភាពប្រែប្រួលរបស់គាត់ (ឃ) ការធ្វើលំហាត់

[១៥៤] កថាខណ្ឌ ៦១ នៃសេចក្តីសម្រេចនេះ។

[១៥៥] កថាខណ្ឌ កថាខណ្ឌ ៧៦ នៃសេចក្តីសម្រេចនេះ។

ប្រាណ ដោយមានការវាយតម្លៃ និងដំបូន្មានពីអ្នកឯកទេសព្យាបាលផ្នែកសិរីរៈនៅពេលដែលត្រូវការ និង (ង) ការគាំទ្រដល់ការចូលរួមក្នុងសកម្មភាពដែលគាត់ពេញចិត្ត។ បន្ថែមលើនេះ កម្មវិធីជម្រុញសតិបញ្ញាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវអាចជួយបានដែរ (ប៉ុន្តែកម្មវិធីបែបនេះត្រូវអនុវត្តចំពោះអ្នកដែលបានទទួលការហ្វឹកហាត់ និងស្ថិតនៅក្រោមការត្រួតពិនិត្យ)។ បន្ថែមលើនេះ ការព្យាបាលជង្គង់ និងការឈឺចាប់ខ្នងរបស់ លោកស្រី អៀង ធីរិទ្ធ និងការពិនិត្យតាមដានជាប្រចាំទៅលើសុខភាពរាងកាយរបស់គាត់ គឺជាការសំខាន់ដែលត្រូវធ្វើ។ ការបន្តព្យាបាល លើស្ថានភាពវេជ្ជសាស្ត្រពីរដែលមានអត្ថិភាពរួមគ្នា នឹងធ្វើឱ្យលទ្ធភាពនៃការជាសះស្បើយរបស់គាត់មានការកើនឡើង។ យើងខ្ញុំកត់សម្គាល់ឃើញថា មិនមានអ្នកជំនាញព្យាបាលតាមបែបធ្វើសកម្មភាព នោះទេនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ ប្រសិនបើមានការវាយតម្លៃលើសកម្មភាពនៃការរស់នៅប្រចាំថ្ងៃរបស់គាត់អាចមានប្រយោជន៍ ហើយដំបូន្មានស្តីពីការកែសម្រួលណាមួយទៅលើបរិស្ថានរស់នៅរបស់គាត់ គួរត្រូវស្វែងរក។ ប៉ុន្តែ យើងខ្ញុំមិនជឿជាក់ថា ការធ្វើអន្តរាគមន៍បែបនេះ គឺជាការបន្ទាន់នោះទេ ដោយសារថា លោកស្រី អៀង ធីរិទ្ធ រក្សាកម្រិតនៃការរស់នៅដោយឯករាជ្យដ៏សមហេតុផលមួយ ហើយគាត់ទំនងជាបានទទួលនូវការជួយថែទាំសមរម្យនៅពេលដែលត្រូវការពីបុគ្គលិកមន្ទីរឃុំឃាំង។

៦៥. ជាការកត់សម្គាល់ អ្នកជំនាញមានយោបល់ថា ស្ថានភាពបញ្ញាស្មារតីរបស់ លោកស្រី អៀង ធីរិទ្ធ នាពេលបច្ចុប្បន្ននេះ អាចមានភាពប្រសើរឡើង ប្រសិនបើជនជាប់ចោទទទួលបានការថែរទាំ និងដំបូន្មានទៅតាមកម្មវិធីរបស់អ្នកជំនាញផ្នែកសិរីរៈ។ អ្នកជំនាញខាងវេជ្ជសាស្ត្រក៏កត់សម្គាល់ផងដែរថា "ការបន្តព្យាបាលលើស្ថានភាពវេជ្ជសាស្ត្រពីរដែលមានអត្ថិភាពរួមគ្នានឹងធ្វើឱ្យលទ្ធភាពនៃការជា សះស្បើយរបស់គាត់មានការកើនឡើង"។ ហេតុដូច្នេះ វាអាចមានលទ្ធភាពមួយដែលថាស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ អាចប្រសើរឡើង។ យោងទៅតាមអាណត្តិរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះត្រូវធានាថា ជនជាប់ចោទមិនត្រូវគេចចេញពីការរកយុត្តិធម៌ឡើយ ប្រសិនបើជនជាប់ចោទនៅតែអាចមានឱកាសមានសម្បទាឡើងវិញក្នុងការចូលរួមសវនាការនាពេលខាងមុខនោះ។ អាស្រ័យហេតុនេះ យើងយល់ឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ គួរត្រូវបានទទួលនូវវិធាន ការណ៍នានាដែលត្រូវបានស្នើឡើង នៅក្នុងកថាខ័ណ្ឌទី ៣៨ នៃរបាយការណ៍របស់លោកសាស្ត្រាចារ្យ Fazel។

៦៦. យើងក៏បានកត់សម្គាល់ឃើញផងដែរនូវរបាយការណ៍របស់អ្នកជំនាញដែលថា: "មិនមានអ្នកជំនាញព្យាបាលតាមបែបធ្វើចលនានោះទេនៅក្នុងប្រទេសកម្ពុជា"។ តាមទស្សនៈ

របស់យើង ការិយាល័យរដ្ឋបាលអាចជួលអ្នកជំនាញបរទេសម្នាក់សម្រាប់ការពិគ្រោះយោបល់ទៅលើការព្យាបាលតាមបែបធ្វើចលនានេះ។ ដោយហេតុថា ការព្យាបាលនៅក្នុងមន្ទីរឃុំឃាំងទំនងជាមិនមានប្រសិទ្ធិភាព យើងយល់ឃើញថា ជនជាប់ចោទគួរត្រូវដោះលែងជាបណ្ដោះអាសន្នដើម្បីទទួលការព្យាបាលដូចបានរៀបរាប់ខាងលើនេះនៅគេហដ្ឋាន ឬបញ្ជូនឱ្យទៅព្យាបាលនៅមន្ទីរពេទ្យ។ ទោះជាយ៉ាងណាក្ដី ដើម្បីធានាថា ការព្យាបាលមានប្រសិទ្ធិភាពនោះ ជនជាប់ចោទ អៀង ធីរិទ្ធ គួរបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ពីព្រោះថានៅមន្ទីរពេទ្យអាចធានាបានថាជនជាប់ចោទទទួលបានការព្យាបាលដោយមានការត្រួតពិនិត្យខាងជំនាញវិជ្ជាជីវៈ។ ការធ្វើបែបនេះនឹងធានាឱ្យមានឱកាសច្រើនក្នុងការធ្វើឱ្យស្ថានភាពរបស់ជនជាប់ចោទអាចប្រសើរឡើងវិញហើយ ជាយថាហេតុ ជនជាប់ចោទអាចនឹងមានសម្បទាចូលរួមជំនុំជម្រះបាន។ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យនឹងគ្រាន់ជា ការសម្រាកបណ្ដោះអាសន្នមួយតែប៉ុណ្ណោះ ពិសេសសម្រាប់រយៈពេល ០៦ ខែ ដែលអ្នកជំនាញត្រូវវាយតម្លៃ ឡើងវិញអំពីសមត្ថភាពក្នុងការចូលរួមសវនាការ។ មូលដ្ឋានគតិយុត្តក្នុងការសម្រាកព្យាបាលបណ្ដោះអាសន្ននៅមន្ទីរពេទ្យមានចែងនៅក្នុងមាត្រា ២២៣(១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថាជនជាប់ចោទ "ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគនៅមន្ទីរពេទ្យ"។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថាដីកាបង្គាប់ឱ្យជនជាប់ចោទចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ក៏មាន នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY ផងដែរ។ ជាក់ស្ដែងក្នុងសំណុំរឿង *Kovačević* អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថាជនជាប់ចោទ "ត្រូវទទួលការព្យាបាលនៅមន្ទីរពេទ្យផ្លូវចិត្ត [...]"។ ដីកាបង្គាប់នេះមានសុពលភាព រហូតដល់ពេលអង្គជំនុំជម្រះបានសម្រេចផ្ទេរជនជាប់ចោទទៅអាជ្ញាធរជាតិនៃប្រទេស Serbia[១៥៦]។

---

[១៥៦] រដ្ឋអាជ្ញា ទល់នឹង *Kovačević* សំណុំរឿងលេខ IT-01-42/2-I សេចក្ដីសម្រេចអំពីការដោះលែងជាបណ្ដោះអាសន្ន ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤។ រដ្ឋអាជ្ញា ទល់នឹង *Kovačević* សំណុំរឿងលេខ IT-01-42/2-I សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំបដិសេធដីកាដំណោះស្រាយ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ២។ រដ្ឋអាជ្ញា ទល់នឹង *Kovačević* សំណុំរឿងលេខ IT-01-42/2-I សេចក្ដីសម្រេចផ្ទេរសំណុំរឿង អនុលោមតាមវិធាន ១១ ស្ទួន ដោយភ្ជាប់ឧបសម្ព័ន្ធជាសម្ងាត់ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ២៣ និង ៤៨។

៦៧. ជាការយល់ឃើញរបស់យើង ការិយាល័យរដ្ឋបាលគួរត្រូវបានបង្គាប់ឱ្យផ្ទេរជនជាប់ចោទ អៀង ធីរិទ្ធ ទៅមន្ទីរពេទ្យ និង ធានាឱ្យជនជាប់ចោទទទួលបាននូវការព្យាបាល ដូចបានរៀបរាប់នៅក្នុងរបាយការណ៍របស់អ្នកជំនាញខាងលើ។ បន្ទាប់ពីអនុវត្តតាមវិធីសាស្ត្រដូចដែលអ្នកជំនាញផ្នែកវេជ្ជសាស្ត្រណែនាំ និងបន្ទាប់ពីរយៈពេលប្រាំមួយខែនៃការសម្រាកព្យាបាលនេះ យើងនឹងពិនិត្យមើលទៅលើស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ ជាថ្មីថា តើគាត់អាចចូលរួមសវនាការបានឬមិនបាន។ ដោយហេតុថា ការដោះលែងមានលក្ខណៈជាបណ្ដោះអាសន្ននោះ លក្ខខណ្ឌមួយចំនួននឹងត្រូវយកមកអនុវត្តភ្ជាប់ទៅនឹងលក្ខខណ្ឌនៃការដោះលែងនេះផងដែរ:

១. មិនត្រូវមានទំនាក់ទំនង ឬពាក់ព័ន្ធជាមួយជនរងគ្រោះ សាក្សី ឬក្រុមគ្រួសារ របស់ពួកគេនោះឡើយ។

២. ត្រូវស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣. ត្រូវចូលរួមក្នុងគ្រប់កិច្ចដំណើការនីតិវិធីនាពេលខាងមុខ នៅពេលណាអង្គជំនុំជម្រះកោះហៅ។

៤. មិនត្រូវធ្វើទំនាក់ទំនងជាមួយសារព័ត៌មាន ឬជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការ។

និងស្នើដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យធានាសន្តិសុខ ដល់ជនជាប់ចោទ អៀង ធីរិទ្ធ អនុលោមតាមមាត្រា ២៤ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

៦៨. ក្រៅពីលក្ខខណ្ឌទាំងនេះ យើងយល់ឃើញស្របគ្នាជាមួយសហសេវិកអន្តរជាតិ។

## ៤.៨ <u>មតិយោបល់របស់ចៅក្រម Silvia CARTWRIGHT និង Jean-Marc LAVERGNE</u>

៦៩. យើងសរសេរយោបល់ដាច់ដោយឡែកពីគ្នាដូច្នេះ ដោយសារតែយើងមានគំនិតខុសគ្នាពីចៅក្រមជាតិពាក់ព័ន្ធនឹងបច្ច័យនៃការដែលរកឃើញថាលោកស្រី អៀង ធីរិទ្ធ ពុំមានសម្បទាដើម្បីចូលរួមក្នុងសវនាការ។

៧០. ជាបឋម យើងសូមគូសបញ្ជាក់ថា ស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ ទំនងជាពុំមានភាពល្អប្រសើរ ឡើងវិញបាននោះទេ នេះបើយោងតាមការខិតខំប្រឹងប្រែងយ៉ាងច្រើនរបស់វេជ្ជបណ្ឌិតដែលមើលថែទាំគាត់ និងដូចអ្វីដែលបានកត់សម្គាល់ដោយអ្នកជំនាញដែលត្រូវបានចាត់តាំងដោយតុលាការ។ អ្នកជំនាញទាំងអស់សុទ្ធតែបានយល់ស្របគ្នាថា លោកស្រី អៀង ធីរិទ្ធ មានជំងឺ

Alzheimer ដែលជាស្ថានភាពធ្លាក់ចុះដុនដាបជាលំដាប់មួយ ដែលទីបញ្ចប់នឹងវិវឌ្ឍទៅជាជំងឺវង្វេងវង្វាន់ស្មារតី។ អ្នកជំនាញទាំងអស់សុទ្ធតែបានពិចារណាការកមើលរោគសញ្ញាដទៃទៀត គឺជំងឺវង្វេងវង្វាន់ស្មារតីដោយសារបញ្ហាសរសៃឈាម ប៉ុន្តែបើយោងតាមការវិនិច្ឆ័យរោគតាមបែបវេជ្ជសាស្ត្រ ពួកគាត់បានកំណត់ថាលោកស្រី អៀង ធីរិទ្ធ ទំនងជាមានជំងឺ Alzheimer។ អ្នកជំនាញខាងវិកលវិទ្យាបានគូសបញ្ជាក់ថា "ការចុះខ្សោយខ្លាំងជាលំដាប់" ដែលពួកគាត់បានកត់សម្គាល់ឃើញគឺ"មានភាពស៊ីគ្នាទៅនឹងជំងឺ Alzheimer ជាងជំងឺវង្វេងវង្វាន់ស្មារតីដោយសារបញ្ហាសរសៃឈាម និងបានលើកឡើងបន្ថែមទៀតថា ជំងឺ Alzheimer គឺជាទម្រង់នៃជំងឺវង្វេងវង្វាន់ស្មារតីដែលមិនអាចវិលត្រឡប់មករកសភាពល្អប្រសើរឡើងវិញ ឬព្យាបាលបាននោះទេ[១៩៧]។

៧១. ទោះបីជាអ្នកជំនាញទាំងអស់សុទ្ធតែបានយល់ស្របគ្នាលើការវិភាគឃើញរោគសញ្ញានៃជំងឺ Alzheimer យ៉ាងណាក្តី ក៏ពួកគាត់សុទ្ធតែបានពិនិត្យឡើងវិញនូវការព្យាបាលលើលោកស្រី អៀង ធីរិទ្ធ នាពេលថ្មីៗនេះផងដែរ។ ពួកគាត់យល់ស្របគ្នាថា ការសម្រេចរបស់គ្រូពេទ្យព្យាបាលលោកស្រី អៀង ធីរិទ្ធ ក្នុងការកាត់បន្ថយការប្រើប្រាស់ឱសថព្យាបាលជំងឺផ្លូវចិត្តរបស់លោកស្រី គឺជាការសម្រេចសមស្របមួយតាមបែបវេជ្ជសាស្ត្រ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីការបន្ថយឱសថទាំងនេះមួយរយៈ ស្ថានភាពសតិបញ្ញារបស់លោកស្រី អៀង ធីរិទ្ធ ពុំមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់នោះទេ។ ទោះបីជាសាស្ត្រាចារ្យ CAMPBELL ស្នើឱ្យសាកល្បងប្រើឱសថ Donepezil យ៉ាងណាក្តី ក៏គាត់គូសបញ្ជាក់ថា ឱសថនេះមានប្រសិទ្ធិភាពតែ ៣០ ភាគរយ ប៉ុណ្ណោះទៅលើអ្នកដែលប្រើប្រាស់វា។ ឱសថនេះនឹងមិនធ្វើឱ្យផ្លាស់ប្តូរស្ថានភាពរបស់គាត់នោះទេ ប៉ុន្តែវាអាចជួយឱ្យការចងចាំរបស់គាត់មានភាពល្អប្រសើរខ្លះតែប៉ុណ្ណោះ។

៧២. អ្នកជំនាញទាំងអស់សុទ្ធតែយល់ស្របគ្នាថា វិធានការព្យាបាលចុងក្រោយដែលនៅមាន គឺមានតែចាប់ផ្តើមកម្មវិធីព្យាបាលដោយឱ្យគាត់ធ្វើសកម្មភាពផ្សេងៗ និងធ្វើយ៉ាងណាឱ្យគាត់បានស្ថិតក្នុងបរិយាកាសដែលអាចជម្រុញឱ្យគាត់មានភាពសកម្មជាងមុន ជាងស្ថានភាពដែលមានក្នុងមន្ទីរឃុំឃាំងនាពេលបច្ចុប្បន្ន[១៩៨]។ ការព្យាបាលដោយឱ្យអ្នកជំងឺធ្វើសកម្មភាពផ្សេងៗ គឺមិនមែនជា

---

[១៩៧] របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ៣៦។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១២៩។

[១៩៨] ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រទី ៥៣ (វេជ្ជបណ្ឌិត Fazel យល់ស្របផងដែរថា ស្ថានភាពរស់នៅរបស់

មុខជំនាញជាអាជីព ដែលមានគេអនុវត្តនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះទេ។ ដូច្នេះ ជម្រើសក្នុងការព្យាបាលតាមវិធានការនេះ គឺមិនអាចធ្វើទៅបាននោះទេ។ អ្នកជំនាញទាំងអស់សុទ្ធតែយល់ឃើញដូចគ្នាថា បរិយាកាសដែលមានលក្ខណៈជម្រុញសកម្មភាពលោកស្រី អៀង ធីរិទ្ធឱ្យសកម្មជាងមុនគឺអាចធ្វើទៅបាន ទាល់តែគេដោះលែងគាត់ឱ្យវិលទៅកាន់គេហដ្ឋានគាត់វិញតែប៉ុណ្ណោះ។ ចៅក្រមអន្តរជាតិកត់សម្គាល់សំណើរបស់ចៅក្រមជាតិ ដែលចង់បង្គាប់ឱ្យដាក់លោកស្រី អៀង ធីរិទ្ធ ឱ្យស្ថិតនៅក្រោមការសម្រាកព្យាបាលនៅឯមន្ទីរពេទ្យ បន្ទាប់ពីគាត់ត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ប៉ុន្តែចៅក្រមអន្តរជាតិពិចារណាឃើញថា ស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ នឹងទំនងជាពុំមានភាពល្អប្រសើរឡើងវិញនោះទេ ទោះបីជាគាត់បានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ មិនចំពោះថាគេអនុវត្តវិធានការវេជ្ជសាស្ត្រ ឬវិធានព្យាបាលផ្សេងណាមួយនោះទេ គ្មានវិធានការណាមួយក្នុងចំណោមវិធានការទាំងនេះ នឹងអាចផ្លាស់ប្តូរ ឬព្យាបាលកម្រិតជំងឺវង្វេងវង្វាន់ស្មារតីរបស់គាត់ក្នុងពេលបច្ចុប្បន្ន ប្រកបដោយប្រសិទ្ធិភាពបាននោះទេ។ អ្នកជំនាញបានគូសបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីដំណាក់កាលទី ៥ ក្នុងចំណោមតំណាក់កាលទាំង ៧ ឬ "តំណាក់កាលដំបូងនៃជំងឺវង្វេងវង្វាន់ស្មារតី៖ ការចុះខ្សោយសតិបញ្ញាកម្រិតធ្ងន់មធ្យម" និងស្ថានភាពនេះនឹងបន្តចុះដុនដាបជាលំដាប់។ ដោយសារហេតុផលទាំងអស់នេះ យើងយល់ស្របគ្នាជាមួយនឹងសហការីជាតិរបស់យើងថា លោកស្រី អៀង ធីរិទ្ធ ពុំមានសម្បទាក្នុងការចូលរួមក្នុងសវនាការទេ និងត្រូវតែដោះលែងគាត់។

៧៣. ប៉ុន្តែ យើងមានយោបល់មិនស្របគ្នា ពាក់ព័ន្ធនឹងវិធានការចាប់បង្ខំដែលសហការីរបស់យើងចង់ឱ្យយកមកអនុវត្តធ្វើជាលក្ខខណ្ឌសម្រាប់ការដោះលែងគាត់។ សហការីជាតិរបស់យើងស្នើឡើងថា

---

លោកស្រី អៀង ធីរិទ្ធ នៅក្នុងមន្ទីរឃុំឃាំង អាចប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងមុខងារបញ្ញាស្មារតីរបស់គាត់ជាទូទៅ ដោយសារតែ "ការធ្វើឱ្យសតិបញ្ញាមានភាពសកម្ម គឺជាផ្នែកសំខាន់មួយក្នុងការធ្វើឱ្យកាត់បន្ថយការចុះអន់ខ្សោយនៃសតិបញ្ញា")។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ២០ ("បញ្ហាលំបាកមួយក្នុងចំណោមបញ្ហាជាច្រើន គឺថាបរិយាកាសក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ គេហាក់ពុំបានគិតគូរធ្វើតេស្តរកមើលស្ថានភាពនៃសកម្មភាពរស់នៅប្រចាំថ្ងៃរបស់លោកស្រី អៀង សារី ឱ្យបានដុំកំភួនអ្វីទាល់តែសោះ") និងប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ១៣១ (*ដោយគូសបញ្ជាក់ថា* ការខ្វះការជម្រុញការធ្វើចលនាក្នុងមន្ទីរឃុំឃាំង គឺជាកត្តាមួយដែលមិនបានជួយអ្វីដល់មុខងារបញ្ញានោះឡើយ)។

លោកស្រី អៀង ធីរិទ្ធ គប្បីត្រូវបានដោះលែងពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ប៉ុន្តែត្រូវបង្គាប់ឲ្យគាត់ចូលសម្រាកព្យាបាលនៅឯមន្ទីរពេទ្យ ភ្លាមបន្ទាប់ពីគាត់ត្រូវបានដោះលែង និងថា ដោយសារតែប្រទេសកម្ពុជាពុំមានអ្នកជំនាញវេជ្ជសាស្ត្រប្រភេទនេះ ខាងការិយាល័យរដ្ឋបាលគប្បីរកអ្នកជំនាញអន្តរជាតិដែលមានគុណវុឌ្ឍិមួយរូប ដើម្បីដាក់កម្មវិធីស្តារសតិបញ្ញាដែលមានការរៀបចំត្រឹមត្រូវមួយសម្រាប់លោកស្រី អៀង ធីរិទ្ធ និងថា អង្គជំនុំជម្រះសាលាដំបូង គប្បីពិនិត្យឡើងវិញនូវសមត្ថភាពចូលរួមក្នុងសវនាការរបស់គាត់ក្នុងរយៈពេល ៦ ខែបន្ទាប់។ មិនតែប៉ុណ្ណោះ សហការីជាតិ ស្នើឲ្យបង្គាប់ឲ្យលោកស្រី អៀង ធីរិទ្ធ សម្រាកព្យាបាលផ្នែកវេជ្ជសាស្ត្រ និងស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាជាអ្នកទទួលខុសត្រូវចំពោះសន្តិសុខរបស់គាត់ ដោយអនុលោមទៅតាមមាត្រា ២៤ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

៧៤. ចៅក្រមអន្តរជាតិ ពិចារណាឃើញថា ពុំមានមូលដ្ឋានគតិយុត្តិណាមួយ ដែលតម្រូវបង្គាប់ឲ្យលោកស្រី អៀង ធីរិទ្ធ ចូលសម្រាកក្នុងមន្ទីរពេទ្យនោះទេ។ សហសេវិកជាតិរបស់យើង បានលើកឡើងនូវមាត្រា ២២៣ (១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ ជាមូលដ្ឋានក្នុងការចាត់វិធានការដាក់ការព្យាបាលដោយបង្ខំទៅលើជនជាប់ចោទ។ យើងយល់ថា មាត្រានេះគឺមិនអាចអនុវត្តបានទេនៅក្នុងស្ថានភាពបច្ចុប្បន្ននេះ។ មាត្រា ២២៣ នេះ អនុញ្ញាតឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះការឃុំខ្លួនមុនការចាប់ផ្តើមការជំនុំជម្រះ[១៥៩]។ មាត្រានេះ មិនអនុវត្តបានទៀតទេ នៅពេលដែលអង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទណាម្នាក់គ្មានសម្បទាក្នុងការចូលរួមសវនាការ ហើយកិច្ចដំណើការនីតិវិធីត្រូវបានផ្អាក ដោយគ្មានមូលហេតុសមស្របថា នឹងមានការជំនុំជម្រះក្តីលើរូបគាត់ឡើងវិញបាននោះ។ តាមការយល់ឃើញរបស់យើង ក្របខណ្ឌច្បាប់សម្រាប់អនុវត្តនៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងមិនអាចដាក់ជនជាប់-ចោទឲ្យស្ថិត នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយ។

៧៥. សហសេវិកជាតិបានលើកឡើងនូវករណី *Kovačević* ដើម្បីគាំទ្រការបញ្ជូនជនជាប់ចោទទៅព្យាបាលនៅមន្ទីរពេទ្យ។ នៅក្នុងករណីនៃរឿងក្តីខាងលើនេះ ជនជាប់ចោទ *Kovačević* ត្រូវបានដោះលែងជាបណ្តោះអាសន្នពីការឃុំខ្លួនដោយតុលាការ ICTY ដើម្បីទទួលការព្យាបាលជំងឺ

---

[១៥៩] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

ផ្លូវចិត្តនៅប្រទេស Serbia[១៦០] ដែលជាប្រទេសកំណើតរបស់លោក។ ខុសពីសំណុំរឿងក្តីចំពោះមុខអង្គជំនុំជម្រះនាពេលនេះ នៅក្នុងរឿងក្តី *Kovačević* រដ្ឋអាជ្ញា និងមេធាវីការពារក្តីសុទ្ធតែយល់ស្របគ្នាថា ជនជាប់ចោទរូបនេះស្ថិតក្នុងស្ថានភាពមួយ ដែលតម្រូវឱ្យមានការព្យាបាលនៅមន្ទីរពេទ្យវិកលវិទ្យា[១៦១]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានរកឃើញថា ជនជាប់ចោទមានជំងឺនៃការធ្លាក់ចុះខ្សោយផ្នែក បញ្ញា ស្មារតី ជាលំដាប់ ហើយជំងឺនេះទំនងជាមិនអាចមានភាពប្រសើរឡើងវិញនោះទេ។ ជាងនេះទៅទៀត មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ មិនបានស្នើសុំឱ្យបញ្ជូនជនជាប់ចោទទៅព្យាបាលនៅមន្ទីរពេទ្យ និងស្នើសុំដាក់ក្រោមការធានាសន្តិសុខពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាឡើយ។ អង្គជំនុំជម្រះសាលាដំបូងមិនមានមូលដ្ឋានគតិយុត្តណាមួយដើម្បីដាក់ជនជាប់ចោទរូបនេះស្ថិតនៅក្នុងការព្យាបាលដោយបង្ខំនៅមន្ទីរពេទ្យ ឬមួយក៏ទម្រង់ផ្សេងទៀតនៃការដាក់ដោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[១៦២]។ ហេតុដូច្នេះ យើងមិនអាចយល់ស្របជាមួយនឹងការសម្រេចដោះលែងដោយមានការដាក់ លក្ខខណ្ឌបែបនេះទៅលើជនជាប់ចោទនោះឡើយ។

៧៦. ដោយពិចារណាលើកត្តាខាងលើ យើងនឹងបង្គាប់ឱ្យដោះលែងលោកស្រី អៀង ធីរិទ្ធ អនុលោម

---

[១៦០] រដ្ឋអាជ្ញា ទល់នឹង *Kovačević* សំណុំរឿងលេខ IT-01-42/2-I សេចក្តីសម្រេចអំពីការដោះលែងជាបណ្តោះអាសន្ន ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ ១។

[១៦១] រដ្ឋអាជ្ញា ទល់នឹង *Kovačević* សំណុំរឿងលេខ IT-01-42/2-I អត្ថបទនៃសេចក្តីសម្រេចជាសាធារណៈស្តីពីសមត្ថភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ១០។

[១៦២] វិធាន ២១(២) នៃវិធានផ្ទៃក្នុង។ មិនមានភស្តុតាងដែលបង្ហាញថា លោកស្រី អៀង ធីរិទ្ធ បង្ករហានីភ័យដល់ខ្លួនឯង ឬដល់អ្នកដទៃឡើយ។ ហេតុដូច្នេះ វិធានការពាក់ព័ន្ធនឹងសុវត្ថិភាពរបស់ជានជាប់ចោទគឺមិនតម្រូវនោះទេ។ នៅក្នុងករណីណាក៏ដោយ មូលដ្ឋានគតិយុត្តរបស់ អ.វ.ត.ក មិនបានអនុញ្ញាតឱ្យតុលាការព្រហ្មទណ្ឌធ្វើដូច្នេះទេ ប៉ុន្តែគេអាចឃើញវិធានការបែបនេះ មានចែងនៅក្នុងច្បាប់ដែលអនុវត្តដោយតុលាការរដ្ឋបាល ឬតុលាការរដ្ឋប្បវេណី នៅពេលដែលបុគ្គលម្នាក់ស្ថិតក្នុងស្ថានភាពដែលតម្រូវឱ្យមានការព្យាបាល។

ទៅតាមវិធាន ៨២(៦) នៃវិធានផ្ទៃក្នុង។

## ៤.៩ <u>បច្ច័យនៃយោបល់ដាច់ដោយឡែកពីគ្នារបស់ចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ស្តីពីបញ្ហាដោះលែង</u>

៧៧. អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របគ្នាជាឯកច្ឆន្ទថា លោកស្រី អៀង ធីរិទ្ធ ពុំមានសម្បទាក្នុងការចូលរួមក្នុងសវនាការនោះទេ ហើយនីតិវិធីប្រឆាំងនឹងរូបគាត់ត្រូវផ្អាក។ ចៅក្រមទាំងអស់បានយល់ស្របគ្នាថា គាត់មិនអាចត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក តទៅទៀតបានឡើយ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមជាតិ មានបំណងដាក់លក្ខ ខណ្ឌភ្ជាប់ទៅនឹងការដោះលែងនេះ ជាពិសេសនោះគឺការបង្គាប់ឱ្យបញ្ជូនជនជាប់ចោទរូបនេះទៅព្យាបាលនៅមន្ទីរពេទ្យជាមួយនឹងការស្នើឱ្យមានការវាយតម្លៃសម្បទារបស់គាត់ឡើងវិញក្នុងរយៈពេលប្រាំមួយខែក្រោយពីការព្យាបាល។ បញ្ជាក់សេចក្តីសម្រេចនោះ ដោយបានគូសបញ្ជាក់ថាលោកស្រី "គ្មានសម្បទាក្នុងពេលឥឡូវនេះ" ប៉ុន្តែចៅក្រមអន្តរជាតិរកមិនឃើញភ័ស្តុតាងជាមូលដ្ឋានណាមួយ ដើម្បីសម្រេចថាលោកស្រី នឹងត្រឡប់ជាមានសម្បទាចូលរួមក្នុងសវនាការវិញបាននៅថ្ងៃអនាគតនោះទេ។

៧៨. អ្នកជំនាញវេជ្ជសាស្ត្រទាំងអស់សុទ្ធតែបានយល់ស្របគ្នាថា ជនជាប់ចោទទំនងជានឹងមិនអាចសម្បទាល្អប្រសើរឡើងវិញក្នុងការចូលរួមសវនាការនាពេលអនាគតនោះទេ ហើយចៅក្រមអន្តរជាតិការផ្អាកកិច្ចដំណើការនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះទំនងជាមានលក្ខណៈអចិន្ត្រៃយ៍។ ដោយហេតុថាទំនងជាមិនអាចមានហេតុផលសមរម្យដើម្បីជំនុំជម្រះជនជាប់ចោទបានទេនោះ ចៅក្រមអន្តរជាតិយល់ឃើញថា ពួកខ្លួនមិនមានហេតុផលអ្វីដើម្បីបន្តឃុំខ្លួនជនជាប់ចោទ ឬ ដាក់វិធានការណ៍បង្ខំនានាចំពោះ អៀង ធីរិទ្ធ បានឡើយ[១៦៣]។ ហេតុដូច្នេះ មិនមានមូលដ្ឋានសម្រាប់ការឃុំឃាំង ជនជាប់ចោទ ឡើយ។ តាមទស្សនៈរបស់ចៅក្រមអន្តរជាតិ គឺត្រូវដោះលែងដោយឥតលក្ខខណ្ឌលើកលែងតែសហព្រះរាជអាជ្ញាស្នើសុំផ្អាកការដោះលែង និងដាក់បណ្តឹងសាទុក្ខភ្លាមៗ ស្របតាមវិធាន ៨២(៦)។

---

[១៦៣] សូមមើល សេចក្តីសម្រេចពាក់ព័ន្ធនឹងការស្នើសុំដោះលែង នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ជាបន្ទាន់ ឯកសារលេខ E50 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ៤១ (ដោយបានបញ្ជាក់ថា គោលបំណងនៃការឃុំខ្លួន អៀង ធីរិទ្ធ គឺដើម្បីធានាថា គាត់នឹងមានវត្តមាននៅសវនាការ)។

00753977



៧៩. លទ្ធផលនៃការដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចឈានទៅយល់ស្របគ្នាបានលើចំណុចថាតើអង្គជំនុំជម្រះមានយុត្តាធិការក្នុងការកំណត់លក្ខខណ្ឌលើការដោះលែងគាត់ឬយ៉ាងណានោះ គឺថាអង្គជំនុំជម្រះរកពុំបានសម្លេងភាគច្រើន ដោយអនុលោមទៅតាមមាត្រា ១៤(១)(ក) នៃច្បាប់ អ.វ.ត.ក។ ស្របតាមបទបញ្ញត្តិនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានសម្រេចភាគច្រើនលើសលុបរបស់ចៅក្រមយ៉ាងតិចបួន[១៦៤] ។ ប៉ុន្តែ អង្គជំនុំជម្រះមិនអាចរកការ ព្រមព្រៀងបានលើបច្ច័យដែលកើតចេញពីអវត្តមាននៃសម្លេងលើសលុប។ ប៉ុន្តែ លទ្ធផលក្នុងករណីដែលមិនមានសម្លេងយល់ព្រមលើបច្ច័យនៃការមិនព្រមព្រៀង មិនមានចែងក្នុងកិច្ចព្រមព្រៀង ឬ ច្បាប់ទេ[១៦៥]។ ដោយភាពតែមួយនៃបទបញ្ញត្តិសម្លេងលើសលុបនៅ អ.វ.ត.ក ហើយ ក៏មិនមានយុត្តិសាស្ត្រអន្តរជាតិ ឬ គោលការណ៍ប្រហាក់ប្រហែលនៅក្នុងច្បាប់កម្ពុជា។ ហេតុដូច្នេះចៅក្រមអង្គជំនុំជម្រះត្រូវរកបទបញ្ញត្តិគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្សដើម្បីកំណត់នូវលទ្ធផលនៃសេចក្តីសម្រេចសម្រាប់ជនជាប់ចោទ[១៦៦]។

៨០. ដោយអវត្តមាននៃការណែនាំនៅក្នុងច្បាប់ អ.វ.ត.ក អង្គជំនុំជម្រះបានរកឃើញថា ស្តង់ដា

---

[១៦៤] មាត្រា ១៤(១)(ក) ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖ (១) ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងការសម្រេចសេចក្តីរបស់ខ្លួន។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះ ពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ (ក) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច។

[១៦៥] វិធាន ៩៨(៤) នៃវិធានផ្ទៃក្នុងចែងពាក់ព័ន្ធនឹងការសម្រេចអំពីការផ្តន្ទាទោស ចែងថា ប្រសិនបើរកសម្លេងភាគច្រើនតាមការតម្រូវមិនបានទេនោះ មានន័យថា ជនជាប់ចោទត្រូវរួចផុតពីបទចោទ។ សូមមើលផងដែរ សំណុំរឿងលេខ ០០១/ ១៨ កក្កដា ២០០៧/ អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីស្តីពីអាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ។ ឯកសារ E187 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៦ (ដោយយល់ឃើញជាឯកច្ឆ័ន្ទថា ការមិនអាចឈានទៅដល់ការឯកភាពគ្នាលើអាជ្ញាយុកាលនៃបទឧក្រិដ្ឋជាតិនោះ នាំឱ្យបង្កើតជាឧបសគ្គក្នុងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក។

[១៦៦] មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក (“ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំមានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ [...] គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”)។

អន្តរជាតិជាសារវន្តខាងលើដែលតម្រូវឲ្យដោះលែងជនជាប់ចោទ អនុលោមតាមវិធាន ៨២(៦)។ ទី១ អង្គជំនុំជម្រះកត់សម្គាល់ថា នៅក្នុងលក្ខន្តិកៈចែងថា នៅពេលដែលការបកស្រាយបញ្ញត្តិច្បាប់មានទំនាស់គ្នា ការបង្កើតតឹងរឹងនៃលក្ខន្តិកៈព្រហ្មទណ្ឌតម្រូវឲ្យការបកស្រាយត្រូវផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ[១៦៧]។ ស្របតាមគោលការណ៍នៃការសន្មត់ថា គ្មានទោសសេរីភាពគឺជាវិធាន រីឯការឃុំឃាំងគឺជាវិធានការណ៍វិសាមញ្ញ ដែលត្រូវដាក់ស្របតាមនីតិវិធីដែលបង្កើតដោយច្បាប់[១៦៨]។ អង្គជំនុំជម្រះយល់ស្របគ្នាថា អៀង ធីរិទ្ធ មិនមានសម្បទាចូលរួមជំនុំជម្រះ និងជាបច្ច័យ ផ្អាកនីតិវិធីចំពោះគាត់។ ការបន្តការឃុំខ្លួន ឬការដាក់ឃុំឃាំងដោយបង្ខំនៅក្នុងស្ថានភាពដែលមិនច្បាស់លាស់ថា តើអង្គជំនុំជម្រះនឹងត្រូវធ្វើសវនការពេលណានោះ គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ ចំពោះការជម្រះក្តីដោយយុត្តិធម៌[១៦៩]។

៨១. ហេតុដូច្នេះ អង្គជំនុំជម្រះគប្បីដោះលែង ជនជាប់ចោទ អៀង ធីរិទ្ធ។ អវត្តមាននៃការព្រមព្រៀងអំពីលក្ខខណ្ឌចំពោះការដោះលែង គឺនាំឲ្យស្ថានភាពរបស់ជនជាប់ចោទមិនច្បាស់លាស់។ ជាលទ្ធផលនៃសេចក្តីសម្រេចនេះ ផ្ទុយទៅវិញ ប្រសិនបើ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានរក្សាទុកនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ឬ ដាក់ឲ្យព្យាបាលដោយបង្ខំនៅមន្ទីរពេទ្យលទ្ធភាពដែលអាចកើតមាននោះ គឺថា ការបន្តឃុំឃាំងមិនមានមូលដ្ឋានច្បាប់ទេ។ ដើម្បីកុំឲ្យមានបញ្ហានេះ អង្គជំនុំជម្រះយល់ស្របគ្នាថា នៅក្នុងស្ថានភាពនេះត្រូវ ដោះលែងជនជាប់ចោទ។

៨២. យើងសូមគូសបញ្ជាក់ថា ការរកឃើញភាពគ្មានសម្បទាចូលរួមក្នុងសវនាការនេះ ពុំមែនជាការរកឃើញអំពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នោះឡើយ។

---

[១៦៧] សូមមើល រដ្ឋអាជ្ញា ទល់នឹង *Zejnil Delalić* និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-96-21-T សាលក្រម ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤១៣ (ក្នុងការបកស្រាយតឹងរឹងនៃច្បាប់ព្រហ្មទណ្ឌ នៅពេលណាដែលមានមានមិនច្បាស់លាស់ចំពោះអត្ថន័យនៃពាក្យ ឬឃ្លាប្រយោគណាមួយនោះ ភាពបន្ទិលនោះនឹងត្រូវបកស្រាយប្រឆាំងទៅនឹងអ្នកបង្កើតច្បាប់ដែលបានអនុម័តច្បាប់ដោយបង្កប់នូវភាពបន្ទិល។

[១៦៨] មាត្រា ៩ នៃកតិការសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ។

[១៦៩] មាត្រា ៩(៣) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ។

**អាស្រ័យដូចបានពោលក្នុងសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**សម្រេចថា** ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាក្នុងការចូលរួមសវនាការទេ។

**បង្គាប់** ឲ្យបំបែកបទចោទប្រឆាំងលើជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ ដោយអនុលោមទៅតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង។

**ប្រកាស** ផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២ និង

**ប្រកាសបន្ថែមថា** អង្គជំនុំជម្រះមិនអាចរកសេចក្ដីសម្រេចជាឯកច្ឆន្ទបានឡើយចំពោះ ថាតើអង្គជំនុំជម្រះសាលាដំបូងគប្បីបង្គាប់ឲ្យយកជនជាប់ចោទ អៀង ធីរិទ្ធ ទៅព្យាបាលដោយបង្ខំនៅក្នុងមន្ទីរពេទ្យ ឬថាតើគាត់គួរតែត្រូវបានដោះលែងដោយគ្មានលក្ខខណ្ឌ។

**រកឃើញថា** អវត្តមាននៃការព្រមព្រៀងអំពីថា តើអង្គជំនុំជម្រះត្រូវដាក់លក្ខខណ ឬ មិនដាក់លក្ខខណ្ឌនៅពេលដោះលែងនោះ គឺ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវដោះលែងពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ស្របតាមការសម្រេចនេះ។

**បង្គាប់** ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ។

**ប្រាប់** ជនជាប់ចោទនូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមវិធានផ្ទៃក្នុង ៣៥ ដោយមិនឲ្យជ្រៀតជ្រែករដ្ឋបាលយុត្តិធម៌ ហើយជាពិសេស ការទាក់ទងជាមួយសាក្សី ឬ សាក្សីសក្ដានុពលរបស់ អ.វ.ត.ក។

**បង្គាប់** ឲ្យជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះ មុននឹងប្ដូរអាសដ្ឋានទៅកន្លែងផ្សេង។

**ជំរាបមក** សហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញា អាចស្នើសុំឲ្យអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញឲ្យធ្វើការវាយតម្លៃជនជាប់ចោទ អៀង ធីរិទ្ធ ឡើងវិញ តាមរយៈកាល និង អាចស្នើសុំឲ្យអង្គជំនុំជម្រះចាប់ផ្ដើមដំណើរការនីតិវិធីចំពោះជនជាប់ចោទ អៀង ធីរិទ្ធ នៅដំណាក់កាលណាមួយក៏បាន នៅពេលដែល

មានការបង្ហាញថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ មានការផ្លាស់ប្តូរ។ ដើម្បីសម្រេចគោលដៅនេះ សហព្រះរាជអាជ្ញាត្រូវបង្កើតយន្តការត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។

ភ្នំពេញ ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន